

# ប្រវត្តិព្រះវិហារធំសសរ

# 100 Pillar Preah Vihear Thom

រៀបរៀងដោយ អឿ អ៊ិល

Written by Oeur Il

6.4

CCC/2010
306.4



# ប្រវត្តិព្រះវិហារធំសសរ ១០០

## 100 - Pillar Preah Vihear Thom

ប.ក. 20126

រៀបរៀងដោយ អឿ អ៊ីល
Written by Oeur Il

# អារម្ភកថា

ខ្ញុំមានបំណងសរសេរសៀវភៅប្រវត្តិរឿងដែលមានរូបភាពនេះ តាំងពីពេលដែលខ្ញុំបានទៅដល់ព្រះវិហារសសរ១០០ នាឆ្នាំ២០០៤ ជាពេលដែលមានការបើកវគ្គបណ្តុះបណ្តាល "ការរិភាគបញ្ហាអភិវឌ្ឍន៍ (អេនីអាយ)" នៅខេត្តក្រចេះ នៃប្រទេសកម្ពុជា។ នៅពេលដែលខ្ញុំបានព្យាយាម មើលរូបភាពនៅតាមជញ្ជាំង និងពិដាននៃរោងបដិសណ្ឋារកិច្ចក្នុងវត្ត ធ្វើអោយខ្ញុំចាប់អារម្មណ៍យ៉ាងខ្លាំង ហើយបានធ្វើអោយខ្ញុំនឹកឃើញទៅដល់ពេលដែលខ្ញុំបានរៀននៅឯសាលាបឋមសិក្សា ទាក់ទងទៅនឹងមេរៀនមួយស្តីពីក្រពើពីរនាក់គ្នានៅតាមដងទន្លេ ។

ខ្ញុំបានទៅកាន់ព្រះវិហារនេះ៣លើកទៀត ជាមួយក្រុមអេនីអាយក្នុងឆ្នាំ ២០០៧ ដែលរឹតតែធ្វើឱ្យខ្ញុំចាប់អារម្មណ៍កាន់តែខ្លាំង ដោយខ្ញុំបានចំណាយពេលសួរចាស់ទុំច្រើនជាងមុន ប៉ុន្តែខ្ញុំមិនសួរសំណួរដដែលដូចលើកមុនភាគច្រើន ទៅកាន់ចាស់ទុំនៅក្នុងវត្ត ព្រោះខ្ញុំមិនចងចាំរឿងរ៉ាវជាច្រើនដែលបានកើតឡើងនោះទេ។ ហេតុនេះហើយ ទើបធ្វើអោយខ្ញុំបានខិតខំរៀបរៀងប្រវត្តិនេះឡើងសំរាប់លោក-លោកស្រី ព្រមទាំងកុមារា-កុមារីដែលចង់ដឹងបន្ថែមអំពីរឿងនេះ ។

តាមការលើកឡើងរបស់លោកតានៅក្នុងវត្តបានអះអាងថា រឿងនេះគឺជារឿងពិតមួយដែលទាក់ទងទៅនឹងព្រះមហាក្សត្រខ្មែរមួយអង្គ និងព្រះរាជបុត្រី ហើយដែលមានភស្តុតាងដូចជា ចេតិយដែលមានតម្កល់ព្រះអដ្ឋិធាតុស្រាប់។ ខ្ញុំខិតខំសរសេររឿងនេះឡើង គឺពុំមានបំណងអ្វីក្រៅពីកត់ត្រាទុកនូវរឿងរ៉ាវដែលចេះចាំតមាត់គ្នា និងជារឿងមួយដែលបានជំរុញបន្ថែមលើទម្លាប់ ឬជំនឿដែលមានតាំងពីបុរាណកាលដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងសង្គមខ្មែរយើង ជាក់ស្តែងគឺការប្រើប្រាស់ទង់ក្រពើ នៅក្នុងពិធីបុណ្យសពជាដើម ។

ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះ ចំពោះសប្បុរសជនដែលបានឧបត្ថម្ភ ការគូររូបភាពក្នុងវត្ត លោកតាម៉ៅ គឹមហ៊ាន លោកតាអ៊ុក ឡឿន និងលោកតា សោ ម៉ុន រួមជាមួយនិងលោកតាខ្លះទៀតនៅក្នុងវត្តព្រះវិហារធំសសរ១០០ដែល បាននិទានរឿងបន្ថែមពីរលើកទៀតនៅថ្ងៃទី ២៨ មេសា និង ៩ មិថុនា ២០០៧ ព្រមទាំងសូមអរគុណផងដែរចំពោះលោកតា ធុយ ប៊ុនចឹង ដែលផ្តល់បទសម្ភាសន៍ នៅថ្ងៃទី ៤ កក្កដា ២០០៧ និងលោក ជឹម ផាក់ មេឃុំជ័យឧត្តម ព្រមទាំងចាស់ទុំខ្លះទៀត ដែលរស់នៅភូមិស្រែឈូក ឃុំជ័យឧត្តម ស្រុកលំផាត់ និងលោកតាអាចារ្យ លន់ នៅវត្តអារញ្ញារាម ទីរួមស្រុកលំផាត់ដែលលោកទាំងអស់បានផ្តល់ឱកាសឱ្យខ្ញុំបានជួបជាការបង្កលក្ខណៈល្អប្រសើរសំរាប់រូបខ្ញុំសរសេរប្រវត្តិនេះឡើង ។

ខ្ញុំក៏សូមថ្លែងអំណរគុណជាអនេកដល់លោក-លោកស្រី ដែលបានជួយឱ្យការសរសេរសៀវភៅនេះបានសំរេចគឺ លោកថា សុផល លោកគង់ សៀកលី កញ្ញាឈុំ ស៊ីរុម កញ្ញាឃួន ច័ន្ទដួរ កញ្ញាទុយ មុនីរ៉េត លោកអ៊ឹង រតនៈ លោកស្រីឃឹម នីម៉ូល្លា កញ្ញាខាត់ទ្រីណា សោនទ័រ កញ្ញាអេងរដ្ឋា និងការលើកទឹកចិត្តពីសំណាក់ភរិយារបស់ខ្ញុំ ស៊ីម៉ូណារី ព្រមទាំងឪពុកម្តាយជាទីស្រឡាញ់របស់ខ្ញុំ។

ការបោះពុម្ពសៀវភៅនេះមិនអាចធ្វើបានទេ បើគ្មានទឹកចិត្តសប្បុរសរបស់ លោក-លោកស្រី

ចូលរួមបច្ច័យដូចបានរាយនាមនៅខាងសន្លឹកចុងក្រោយស្រាប់ ដើម្បីជាការសន្សំបុណ្យកុសល និង ភ្ជាប់និស្ស័យក្នុងព្រះពុទ្ធសាសនា ព្រោះថាសៀវភៅនេះ នឹងត្រូវយកទៅតម្កល់ទុកជាចម្លងនៅក្នុង វត្តព្រះវិហារធំសសរ១០០ និងវត្តដទៃទៀត ព្រមទាំងគ្រឹះស្ថានសាលារៀនផ្សេងៗ។ នេះពិតជាបង្ហាញ ឲ្យឃើញ នូវមហាកម្លាំងសាមគ្គីមួយដែលធ្វើឲ្យគោលបំណងនេះសំរេចបាន ។

ផ្ទៃរឿងទាំងមូលមានពីរភាសា ដើម្បីងាយស្រួលសំរាប់ខ្មែរយើងក៏ដូចជា ជនបរទេសដែល ចាប់អារម្មណ៍ក្នុងការអានរឿងនេះ។ នៅក្នុងសៀវភៅនេះមាន រូបភាព២៣ ដែលត្រូវបានគូរនៅក្នុង រោងបដិសណ្ឋារកិច្ចក្នុងវត្ត និងឧបត្ថម្ភដោយ សប្បុរសជនជាច្រើននាក់ ហើយខ្ញុំបានបន្ថែមរូបថតនៃ ព្រះវិហារធំសសរ១០០ និង ចេតិយព្រះនាងក្រពុំឈូក ព្រមទាំងទីតាំងពិតៗដែលទាក់ទងនឹង រឿងនេះដែរ។

ព្រះវិហារធំសសរ១០០គឺជាទីកន្លែងវប្បធម៌ល្បីល្បាញមួយក្នុងចំណោមទី កន្លែងឯទៀតនៅក្នុង ខេត្តក្រចេះ ដែលមានភ្ញៀវជាច្រើនបានទៅដល់ទីនោះ។ តាមពិត បើគ្រាន់តែបានមើលឃើញមិន គ្រប់គ្រាន់នោះទេ តែនៅពេលដែលបាន ចំណាយពេលស្តាប់ដោយយកចិត្តទុកដាក់នូវការនិទាន របស់លោកតា នៅក្នុងវត្តនោះ ទើបធ្វើអោយយើងមានអារម្មណ៍គួរចង់តាមដាន និងយល់កាន់តែច្បាស់ ចំពោះភាពសម្បូរបែបនៃវប្បធម៌ និងប្រពៃណីខ្មែរ ។ ដោយឡែក ខេត្តរតនគិរី ក៏ជាខេត្តមួយដែលមាន សក្តានុពលខាងទេសចរណ៍ធម្មជាតិ ព្រោះមានព្រៃព្រឹក្សានិងបឹងធម្មជាតិតូចធំ ព្រមទាំងជាតំបន់ ជនជាតិដើមភាគតិចជាច្រើនក្រុមកំពុង រស់នៅទីនោះដែលគួរទាក់ទាញភ្ញៀវជាតិ និងអន្តរជាតិ ទៅទស្សនា។

ខ្ញុំហាក់ដូចជាបង្ហាញនូវការរៀបរាប់វែងបន្តិច តែខ្ញុំពុំមានគំនិតអ្វីក្រៅពី ចង់អោយលោក-លោកស្រី និង កុមារ-កុមារី មានការចាប់អារម្មណ៍ដូចរូបខ្ញុំ ចំពោះរឿងរ៉ាវដែលមានជិតជាមនៅក្នុង សង្គមខ្មែរយើង។ ខ្ញុំបានព្យាយាមពិគ្រោះ ជាមួយឯកសារពាក់ព័ន្ធ ដើម្បីបញ្ចូលខ្លឹមសារដែលមាន លក្ខណៈដូចគ្នានិងខុសគ្នា សំរាប់លោក-លោកស្រីធ្វើការពិចារណា។ ខ្ញុំសង្ឃឹមថា សៀវភៅនេះនឹង ជួយឲ្យលោកអ្នកអានចងចាំនូវរឿងដ៏ល្អនេះ។ ខ្ញុំមានអារម្មណ៍រីករាយក្រៃលែងដោយបាន ដឹងពីប្រវត្តិដ៏ល្អនេះ ហើយខ្ញុំសង្ឃឹមថា លោក-លោកស្រី នឹងមានអារម្មណ៍ដូចខ្ញុំដែរ។ ខ្ញុំរង់ចាំ ទទួលនូវការផ្តល់យោបល់ក្នុងន័យស្ថាបនា ជាលាយលក្ខណ៍អក្សរ សំរាប់បោះពុម្ពលើកក្រោយទៀត ដើម្បីអោយប្រវត្តិនេះរឹតតែច្បាស់ និងផ្តល់ជាប្រយោជន៍ដល់អ្នកអានទូទៅទាំងជំនាន់នេះ និង ជំនាន់ក្រោយ ។

អៀ អឿល
ភ្នំពេញ ថ្ងៃទី ១១ ខែ កញ្ញា ២០០៨
ទំនាក់ទំនងតាមអ៊ីម៉េល: iloeur2@gmail.com

# PREFACE

It has been my dream to write this pictorial book since my first trip to 100-Pillar Preah Vihear Thom Wat in 2004. I was visiting the Wat while conducting the Analyzing Development Issues (ADI) course in Kratie province, Cambodia. I was inspired as I was glancing through the pictures embedded within the walls and ceilings of what is called a "Reception Hall" of the Wat, as this reminded me of a lesson in primary school where we learned this story about the two crocodiles fighting in the river.

I visited the Wat another three times in 2007, again with the ADI team, and it struck me even more, so I spent time asking many questions to learn more about the history. Although I was asking the elders many questions repeatedly, I came away with unclear memories of the story. This is why I have compiled the story in this pictorial book, and I hope that other people may feel as proud of the history depicted in this Wat, by doing some reading during and after visiting this Wat.

The Elders claimed this to be a true story, connected to a former Cambodian King and his daughter, as manifested by the present Stupa encompassing her remains. My intention for writing this story is to document history, one which has reinforced the cultural practice that remains deeply rooted in Cambodian society, such as the use of crocodile banner in the funeral.

I would like to sincerely thank those who produced the pictures embedded in the reception hall of the Wat and the elders, Mr. Mao KimHean, Mr. Ouk Doeun, Mr. Soa Monn, and some other elders in the 100-Pillar Preah Vihear Wat who shared their story on April 28 and June 9, 2007. Also, I would like to sincerely thank Mr. Chim Phak, the commune chief of Chey Ouddom, Mr. Thuy Buntheurng and other elders, living in Sre Chhouk village, Chey Ouddom commune, Lumphat district who spent time sharing information on July 4, 2007 and Archar Lon in Aranharam Wat in Lumphat district town. They all have made the writing of this story possible.

I would also like to profoundly thank those who have supported me greatly in making this book a reality. They include Tha Sophal, Kung Seakly, Chhum Syrom, Khuon Chan Dore, Toy Monireth, Ung Rattanak, Yim Nimolla, Katrina Saunders, Eng Rotha and of course, the strong encouragement of my wife, Simonavy, and my parents.

The production of this book would not be possible without the generosities of those of you who have financially contributed to this book, a name list appears on the last page. Due to your good deeds these books will be kept at 100-Pillar Preah Vihear Thom Wat, other Wats and public institutions. Together we have reached the goal of producing this publication.

The entire story is bilingual for easy access to Cambodians and foreigners who are interested in learning about the history depicted inside the Wat. This book contains 23 colour

pictures of the paintings within the Wat's reception hall. I added two original photos of 100-Pillar Preah Vihear Thom Wat and Krapum Chhouk's Stupa and other story-related sites as well.

The 100-Pillar Preah Vihear Thom Wat is one of the most well-known cultural sites in Kratie province where there are many visitors' arrivals annually. In fact, for us seeing was not enough but spending time listening to story told by the elders in the Wat made us fully appreciative and feel immersed into the richness of Cambodian culture and tradition. Also, Ratanakiri province provides a highly eco-touristic potential as it is rich in natural forest and lakes and more importantly there are many indigenous communities there; and thus becomes a place worth visiting.

I appear to have provided a very long introduction; however, I hope that this lures you to have as much interest as I do in this story, an important aspect in Khmer culture. I also have consulted relevant documents to present similarities and differences for your thoughts. I hope this book will provide you with clear information and assist to embed this story in your memory. I personally find the story quite fascinating and I hope you all do too. I invite constructive feedback of my writing to ensure future editions are useful to readers.

Oeur Il
Phnom Penh, September 11, 2007
Email: *iloeur2@gmail.com*




រូបទី ១: ផែនទីបន្ទាយលង្វែក - សៀវភៅជនជាតិខ្មែរ ភាគ២ របស់អង្គការស៊ីផា
(Figure 1: sketchy map of Longvek – Khmer Nation, 2nd Series, by SIPAR)



នៅអតីតក្រុងលង្វែក[១] នាសតវត្សទី១៦ មានព្រះរាជាមួយអង្គ ព្រះនាមថា ចន្ទរាជា ឬ អង្គចន្ទទី១[២] ដែលសោយរាជ្យពីឆ្នាំ ១៥១៦-១៥៦៦។ ព្រះអង្គត្រូវបានប្រវត្តិសាស្ត្រចារទុកថាជាស្ថាបនិក ក្រុងលង្វែក ហើយក្រុងនេះមានចំងាយប្រមាណ ៧០គ.ម ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិលេខ៥។ ក្រុងនេះស្ថិតនៅត្រើយខាងលិចនៃទន្លេសាប ជិតឆ្នុកទ្រូចូលទៅបឹងទន្លេសាប។ ព្រះអង្គកសាងក្រុងលង្វែក រយៈពេលពីរឆ្នាំ គឺ ១៥២៧-១៥២៩។ ក្នុងរជ្ជកាលរបស់ព្រះអង្គជាសម័យកាលមួយសម្បូរសប្បាយ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។

In the former Longvek[1] capital in 16th century, there was a King, Preah Ang Chan Reachea or Preah Ang Chan Ty Muoy[2], who reigned from 1516 until 1566. In historical records, he was reputed for his architecture of Longvek capital about 70km from Phnom Penh along National Route 5. Longvek capital located on the west bank of Tonle Sap River and is near Chhnok Trou. The capital was built within two years from 1527-1529. His reign was known to be one of the most glorious times in Cambodian history.

---

១ បច្ចុប្បន្ននេះ ក៏ឃើងឱ្យឈ្មោះថាលង្វែកដែរ តែបានក្លាយទៅឃុំមួយ នៅក្នុងខេត្តកំពង់ឆ្នាំង តាមបណ្តោយផ្លូវជាតិលេខ ៥ ។

២ តាមសៀវភៅជនជាតិខ្មែរ ភាគ២ របស់អង្គការស៊ីប៉ា មិនមានបង្ហាញពីចំនួនបុត្របុំន្មានអង្គនោះទេ តែមានបុត្រាមួយអង្គ ព្រះនាម បរមរាជា ដែលបានសោយរាជ្យបន្តពីព្រះអង្គ ។ តាមឯកសាររបស់លោក ជួប ឃាន អំពីប្រវត្តិព្រះវិហារសសរ ១០០ ចុះថ្ងៃទី ១៥ វិច្ឆិកា ១៩៩៧ ត្រង់ទំព័រ ២ បង្ហាញថា រឿងនេះទាក់ទងទៅនឹងព្រះបាទអង្គចន្ទរាជាទី២ ដែលបានសោយរាជ្យពីឆ្នាំ ១៨០៦-១៨៣៤ នៅក្នុងរាជធានីឧត្តុង្គ ។ ដូចគ្នានេះដែរ ប្រជុំរឿងព្រេងខ្មែរ ភាគទី ៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០១ ត្រង់ទំព័រ ១៨០ បង្ហាញថា រឿងនេះទាក់ទងនឹងព្រះមហាក្សត្រខ្មែរមួយអង្គនៅសម័យឧត្តុង្គ ។

1 By its original name, Longvek is still currently maintained, however has become one of the communes in Kampong Chhnang province along National Route 5

2 SIPAR's history book, Khmer Nation, 2nd Series, does not indicate the number of children Preah Ang Chan Reachea had, however only specifically names a son, Preah Barom Reachea, who reigned after Preah Ang Chan Reachea. Chuop Khean, in his book of 100-Pillar Vihear, dated November 15, 1997, page 2, indicates this story is related to Preah Ang Chan Reachea Ty Pir who reigned from 1806 – 1834 at Ouddong capital. Similarly, the Collection of Khmer Folklores, 5th series, of Buddhist Institute in 2001, page 180 also reveals the story related to a Cambodian King in the Ouddong era.



រូបទី ២ ហោរាទាយលក្ខណៈព្រះនាងវរភក្ត្រ
(Figure 2: Royal prophet predicted the fate for Vorpheak)

ព្រះអង្គចន្ទរាជា ទ្រង់មានបុត្រីបណ្ដូលចិត្តមួយអង្គ ដែលមានសម្រស់ល្អផូរផង់ មានព្រះនាមថា វរភក្ត្រ ឬ តាមប្រជាជនទូទៅស្គាល់ថា ព្រះនាងក្រពុំឈូក ដែលមានព្រះជន្ម១៦ព្រះវស្សា។ ថ្ងៃមួយព្រះនាងបានធ្លាក់ខ្លួនប្រឈួន ដោយគ្មានអ្នកណាម្នាក់អាចព្យាបាល ព្រះនាងឱ្យជាសះស្បើយពីជំងឺដ៏កំណាចនោះឡើយ[៣] ទើបព្រះរាជាទ្រង់បានអោយហោរាជួយកំណត់រកអ្នកខ្លាំងពូកែ ជួយសង្គ្រោះព្រះជន្មរបស់ព្រះនាង ។

Preah Ang Chan Reachea has one lovely daughter, Vorpheak, or publicly known as Krapum Chhouk (Virgin Lotus). She was 16 years old then. One day, she fell badly ill and there was no-one known who had the capacity to cure her illness[3]. Preah Ang Chan Reachea invited the Royal Prophet to predict how to find the best healer to help rid his daughter of this nasty illness.

[៣] តាមឯកសាររបស់លោក ជួប ឃាន ត្រង់ទំព័រ ២-៣ បង្ហាញថា នៅថ្ងៃមួយព្រះរាជាទ្រង់បានត្រាស់ហៅហោរាមកទាយពីលក្ខណៈរបស់បុត្រី ហោរាបានទូលទាយថា ព្រះនាងពុំមានបុណ្យបារមីអ្វីទេ ហើយវានឹងត្រូវក្រពើលេបជាអាសារបង់ នៅពេលដែលព្រះនាងមានព្រះជន្ម ១៨ ព្រះវស្សា ។ លុះដល់ពេញវ័យ ១៨ឆ្នាំ ក៏មានចិត្តចង់ទៅស្រង់ទឹកទន្លេ តែដោយមានការហាមឃាត់ខ្លាំងពេក ទើបបណ្ដាលអោយព្រះនាងមិនសប្បាយព្រះទ័យ រហូតដល់ក្លាយទៅជាប្រឈួនយ៉ាងខ្លាំង ។

[3] Chuop Khean, in his book of 100-Pillar Vihear, dated November 15, 1997 on page 2-3, indicates that Vorpheak was 18 years old when she became ill. Prior to this the King had asked the royal prophet to predict the fate of his young daughter. The prophet claimed she would not be powerful and that she would be swallowed by a crocodile at the age of 18 years. Upon reaching 18 years of age, she wanted to swim at the river but due to strong forbidding of her father, she was very frustrated that she later becomes badly ill.



រូបទី ៣: ព្រះអង្គចន្ទរាជាចាត់សេវកាមាត្យអោយរកអ្នកខ្លាំងពូកែ
(Figure 3: The King ordered Sevakamarts to get the best healer)

*ក្រោយពីបានហោរាទាយដឹងសេចក្តីសព្វគ្រប់ហើយ ព្រះរាជាទ្រង់បានត្រាស់បញ្ជាឱ្យសេវកាមាត្យស្វែងរកអ្នកដែលមានមន្តវិជ្ជាខ្លាំងពូកែខាងព្យាបាលជំងឺដើម្បីមកព្យាបាលព្រះនាង ។ បន្ទាប់មកពួកសេវកាមាត្យ បានដើរជាក្រុម ដោយមានប៉ាវគងទូងស្គរ ពីស្រុកមួយទៅស្រុកមួយ តាមទិសដែលហោរាកំណត់ ដើម្បីរកគ្រូខ្លាំងពូកែបំផុតមកព្យាបាលព្រះនាងឱ្យបាន។*

**After the King was informed about how to find someone who could help his daughter, he immediately ordered the Sevakamarts (palace officials) to look for the most effective healer to cure the illness. The Sevakamarts walked as a group, from one place to another, beating drums throughout the Kingdom, as a means of finding the best healer.**



រូបទី ៤: សេវកាមាត្យនិមន្តព្រះគ្រូទៅព្យាបាលព្រះនាងវរ័ក្ខា

(Figure 4: Sevakamarts invited the head-monk to heal Vorpheak's illness)

តាមហោរាបានបញ្ជាក់ថា បើមានអ្នកណាចេញមកសួរថា "ទូងស្គរ មានការអ្វី អ្នកនោះគឺពិតជាអ្នកខ្លាំងពូកែហើយ "។ ក្រោយពីបានខិតខំស្វែងរកជាយូរថ្ងៃមក សេវកាមាត្យបានជួបព្រះសង្ឃមួយអង្គ ចេះមន្តអាគមខ្លាំងពូកែ និងជាចៅអធិការវត្តនាគសែន[4] ដែលមានទីតាំងនៅតាមដងទន្លេមេគង្គ ហើយព្រះអង្គក៏បានចេញមកសាកសួរនៅពេលគូគេទូងស្គរ។ សេវកាមាត្យបាននិមន្តព្រះអង្គដើម្បីទៅព្យាបាលព្រះនាង ដោយធ្វើដំណើរតាមទូករួមគ្នា។

**The royal prophet advised that if anyone came to ask about the beating of the drum, then this was the best person to heal Vorpheak. The Sevakamarts finally met a powerful monk, who came to talk to them about the beating of the drums, and so he was believed to be the most effective illness healer. He was the head-monk of Wat Neaksen[4]. He was invited to travel by boat, with the Sevakamarts, to cure Vorpheak of her illness.**

---

[4] ស្ថិតនៅក្នុងឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។ ប្រជុំរឿងព្រេងខ្មែរ ភាគទី ៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០១ ត្រង់ទំព័រ ១៧៩ បញ្ជាក់ថា ចៅអធិការវត្តចេះមន្តអាគមពូកែ ហើយចិញ្ចឹមក្រពើមួយដែលទុកដូចជាសិស្សជំនិត រហូតដល់ឈ្មោះថា អាធំ អ្នកខ្លះទៀតហៅថា អាថោង ។

[4] Locates in Chroy Banteay Commune, Prek Prasob District, Kartie Province. The Collection of Khmer Folklores, 5th series, of Buddhist Institute 2001 page 179, showed that the head-monk had great magical knowledge and skills and had nurtured the crocodile meant to be his closest disciple named A-Thom, in other records known as A-Thoang.



រូបទី ៥: ព្រះគ្រូចៅអធិការហៅ នេនធន មកផ្ដែផ្ដាំ
(Figure 5: Head-monk talked to Nen Thonn)

មុននឹងព្រះអង្គនិមន្តចេញពីវត្ត ព្រះគ្រូចៅអធិការអង្គនេះ បានហៅនេនៗទាំងអស់ មកផ្ដាំផ្ញើណែនាំឱ្យខិតខំរៀនសូត្រនូវវិជ្ជាដែល ព្រះអង្គបានបង្រៀនរួចហើយព្រះអង្គក៏ងាកមកប្រាប់ នេនម្នាក់ដែលជាសិស្សជំនិតព្រះនាម ធន មកផ្ដែផ្ដាំប្រគល់កូនសោរសំរាប់បោសសំអាតបន្ទប់និងទូផ្សេងៗ តែព្រះអង្គបានបញ្ជាក់ច្បាស់ថាមិនឱ្យបើកទូសម្ងាត់មួយឡើយ ។ ការហាមឃាត់ដូច្នោះបានធ្វើអោយសិស្សជំនិតអង្គនេះមានការសង្ស័យយ៉ាងខ្លាំង។ មិនយូរប៉ុន្មាន បន្ទាប់ពីព្រះចៅអធិការវត្តនិមន្តចេញផុតទៅ សិស្សជំនិតមិនបានស្ដាប់តាមបណ្ដាំឡើយដោយបានបើកមើលទូនោះ ។ នេនធនបានឃើញគម្ពីរមួយដែលមានបង្ហាញពីរបៀបកាឡាខ្លួនឱ្យទៅជាក្រពើ និងសត្វដទៃទៀតជាច្រើន តែនេនធនមានការចាប់អារម្មណ៍ជាងគេត្រង់គាថាកាឡាខ្លួនឱ្យទៅជាសត្វក្រពើ។

Before leaving the Wat, the head-monk asked all his young disciple monks (Nens) to try to learn the lessons he taught, and then he turned to his closest young disciple monk, Nen Thonn, and told him to take good care by cleaning rooms and the book cabinets but he also told not to open one special cabinet. This made the closest young disciple monk curious. As soon as the head-monk left, the young monk, Nen Thonn, opened the forbidden cabinet and he found a bible which described special methods on how to disguise oneself to be a crocodile and other types of animals but it occurred to him to be fond of a method for becoming a crocodile.



រូបទី ៦: ព្រះគ្រូកំពុងព្យាបាលព្រះនាងវរភ័ក្រ្ត
(Figure 6: The monk was curing Preah Neang Vorpheak)

ព្រះគ្រូចៅអធិការបាននិមន្តតាមពួកសេវាកាមាត្យ រហូតបានទៅដល់ព្រះបរមរាជវាំង ។ ព្រះរាជាទ្រង់មានព្រះរាជហឫទ័យសោមនស្សឥតឧបមា ដោយបានជួបអ្នកខ្លាំងពូកែមកមើលជំងឺបុត្រីរបស់ព្រះអង្គ។ ព្រះគ្រូចៅអធិការ បានចំណាយពេលមួយរយៈ ក្នុងការព្យាបាលជំងឺ របស់ព្រះនាងដែលនៅពេលនោះ ព្រះរាជា ព្រះរាជិនី និងមន្ត្រីរាជវាំង បានតាមដាន និងយកចិត្តទុកដាក់ចំពោះស្ថានភាពជំងឺរបស់ព្រះនាងជាខ្លាំង។

The head-monk traveled all the way to the palace with Sevakamarts. The King was very delighted with the presence of the perceived best illness healer to help his daughter. The head-monk spent time consulting and curing Vorpheak's illness, while The King and The Queen and officials attentively took note of the condition and treatment.



រូបទី ៧: កាលដែល នេនធន ប្រែកាឡាជាក្រពើ
(Figure 7: Nen Thonn disguised himself to be a crocodile)

និយាយពី នេនធនវិញ បន្ទាប់ពីបានរៀនគម្ពីរនេះរួចមក នេនក៏បានសាកល្បង ហើយបានប្រាប់ដល់នេនៗដែលនៅក្បែរនោះថា បើនេនក្លាយទៅជាក្រពើ សូមវាយនឹងដងរែកឫស្សីបីដងនោះនេននឹងក្លាយ ជាមនុស្សវិញមិនខាន ។ បន្ទាប់មក នេនក៏បានប្រែកាឡាទៅជាក្រពើមែន ប៉ុន្តែក្រពើដែលបានប្រែកាឡានោះ មានរាងតូចជាងក្រពើធម្មតា ហើយនៅពេលក្រពើនេនធនត្រូវបានវាយនឹងដងរែកឫស្សីរួច ក៏បានក្លាយទៅជាមនុស្សវិញដែរ។

The young monk decided he wanted to try to disguise himself as a crocodile, and told the rest of the young monks in the Wat that if he became a crocodile, they must beat him with a water-carrying tool called "Dang Rek", made from bamboo, three times so that he returns to the form of a human being. He did try the special method, and it worked, but the crocodile was smaller than the regular ones. Then, the small crocodile was beaten with the Dang Rek by the young monks, he returns as a human being.

ប៉ុន្តែព្រះសង្ឃដែលនៅរង់ចាំជួយបានមានសង្ឃដីការថា "ក្រពើដែល នេនធន កាឡាខ្លួននោះមានរាងតូចណាស់ តើនេនអាចធ្វើអោយខ្លួននេនមានរាងធំជាងនេះទៀតបានទេ?" បន្ទាប់មកនេនធនដោយមានទឹកចិត្តចង់សំដែងឫទ្ធិដែរនោះ ក៏បានសាកល្បងជាលើកទីពីរ[៥] ហើយ មានរូបរាងធំជាងក្រពើធម្មតាមែន។ ម្តងនេះបានធ្វើអោយសង្ឃដែលនៅជិតៗមានការភ័យខ្លាចមិនហ៊ានជួយ និងមិនហ៊ាននៅជិតក្រពើនេនធននោះដែរ។

បន្ទាប់មក ក្រពើនេនធន បានលោតចូលទៅក្នុងទឹក តែបានឡើងចុះនិងមកនៅក្រោមកុដិ ដើម្បីអោយគេមកជួយ ប៉ុន្តែគ្មាននរណាម្នាក់នៅក្នុងវត្តហ៊ានមកជួយដោយវាយនឹងដងរែកទៀតឡើយ ។ ក្រពើនេនធន ក៏អស់សង្ឃឹមដោយមិនដឹងថា នឹងត្រូវធ្វើអ្វីតទៅទៀតឡើយ ហើយក្រោយមក បានគិតឃើញថា ព្រះគ្រូចៅអធិការវត្តអាចជួយបាននៅក្នុងរយៈពេល៧ថ្ងៃ ប៉ុន្តែគួរអោយសោកស្តាយ នៅពេលដែលគិតឃើញនោះ គឺបានហួសរយៈពេល៧ថ្ងៃទៅហើយ ។ ក្រពើនេនធន ក៏បន្តនៅសំងំក្នុងទឹកដោយរង់ចាំព្រះគ្រូចៅអធិការវត្តនិមន្តមកវិញ ។

The young monks who were nearby and helping said that "the crocodile was too small and can you try to make yourself bigger?" Nen Thonn wanted to show his ability, so he tried the second time[5], this time, the crocodile was much bigger than the regular crocodiles. This frightened all young monks who were supposed to help, as well as other monks of the Wat and therefore no-one dared to use the Dang Rek, and were even afraid to stay nearby.

Thonn, in the form of the crocodile, then jumped into the water to take some time to work out what to do. He went back to the Wat and crawled around looking for help, but no-one dared to help by beating the crocodile with the Dang Rek any more. He was hopeless and did not know what to do. His only thought was that only the head-monk could help him, but only before the 7th day. He realized, in fact, it was already over seven days and so he continued to stay in the river waiting for the head-monk's return.

[៥] ឯកសាររបស់លោក ជួប ឃាន ត្រង់ទំព័រទី ៧ បានបញ្ជាក់ថា មានការសាកល្បងតែម្តងគត់ នៅមាត់ស្រះខាងក្រោយវត្ត ។

[5] In his book on page 7, Chuop Khean, indicates that Thonn only had one try at becoming a crocodile in the pond behind the Wat



រូបទី ៨: មនុស្សម្នាចោមរោមមើលព្រះគ្រូចារក្បាលក្រពើ នេនធន
(Figure 8: people looked on as the head-monk gave power on the head of Thonn crocodile)

ក្រោយពេលព្រះគ្រូចៅអធិការនិមន្តមកវិញ ស្រាប់តែបាត់មិនឃើញនេនធនឡើយ ព្រះអង្គក៏បានសួរទៅលោកនេនៗនៅក្នុងវត្ត ដើម្បីរកជួបនេនធន។ ក្រោយពីដឹងថា នេនធន បានលួចអានគម្ពីរហើយបានក្លាយជាក្រពើនោះ ព្រះគ្រូក៏និមន្តទៅកន្លែងក្រពើនេនធន និងហៅនេនធនអោយមកជួប ។ ក្រពើនេនធនក៏ចេញមកបង្ហាញខ្លួន ហើយយកក្បាលទៅបង្អើលនៅលើមាត់ច្រាំង ក្នុងទីចំពោះព្រះភ័ក្ត្រព្រះគ្រូចៅអធិការ ទើបព្រះគ្រូមានសង្ឃដីការថា វាបានយឺតពេលទៅហើយសំរាប់ធ្វើអោយនេនទៅជាមនុស្សវិញ ព្រោះនេះជាកម្មផលរបស់នេន និងមកពីនេនមិនធ្វើតាមការផ្តែផ្តាំរបស់លោកគ្រូ ។ ប៉ុន្តែព្រះគ្រូបញ្ចុះគាថាបន្ថែមដល់ក្រពើនេនធនដើម្បីឱ្យខ្លាំងពូកែជាងក្រពើដទៃទៀត។

Upon the head-monk return, he did not see Nen Thonn and asked the other young monks about Thonn's whereabouts. After he discovered Nen Thonn had secretly learnt about the bible and had become a crocodile, he asked to Thonn to come up to the land. He told Thonn that it was too late to help him to become a human being again because of his deeds, or '*karma*' and disobedience. However, he blessed Thonn by giving the crocodile more magic power to make him more powerful than the other crocodiles in the water kingdom.



រូបទី ៩: កាលព្រះគ្រូជិៈក្រពើ នេនធន ទៅមើលព្រះនាងវរភ័ក្រ្ត
(Figure 9: The head-monk was on board heading toward seeing Vorpheak)

កន្លងក្រោយមក ដោយសារតែព្រះរោគរបស់ព្រះនាងមិនទាន់បានជាសះស្បើយពីព្រះកាយទាំងស្រុងនៅឡើយ ពួកសេវកាមាត្យក៏បានមកនិមន្តព្រះគ្រូម្តងទៀត។ ម្តងនេះព្រះគ្រូបានបដិសេធមិនធ្វើដំណើររួមគ្នាទៅតាមទូកជាមួយ ពួកសេវកាមាត្យទៀតទេ ដោយព្រះអង្គបានមានសង្ឃដីការថាព្រះអង្គមានជំនិះផ្ទាល់របស់ព្រះអង្គហើយ ។ តាំងពីបានក្លាយជាក្រពើមក នេនធនបានធ្វើជាយាន្តជំនិះយ៉ាងសំខាន់មួយសំរាប់ព្រះគ្រូចៅអធិការ ហើយបាននាំព្រះគ្រូចៅអធិការពីវត្តនាគសែនឆ្ពោះមកកាន់ព្រះបរមរាជវាំងនៅឯលង្វែកដើម្បីព្យាបាលព្រះនាង។

The King's daughter did not fully recover, so the Sevakamarts came back to the Wat to invite the head-monk to help them again. This time, the head-monk declined the offer of taking the boat with Sevakamarts and told them that he had his own transport. Since Thonn had become a crocodile, he had offered to be a vehicle for the head-monk, hence, he was able to take him from the Wat to the Royal Palace in Longvek to assist the King's daughter again.



រូបទី ១០: កាលដែលព្រះគ្រូ ព្យាបាលព្រះនាងវរភ័ក្រ្តលើកទី ២
(Figure 10: The headmonk cured Vorpheak the second time)

ក្នុងពេលដែលព្រះគ្រូនៅព្យាបាលជំងឺអោយព្រះនាងនៅឯព្រះរាជវាំង ក្រពើនេនធន ដែលនៅមាត់ទឹក នៅក្រោមព្រះរាជដំណាក់ផែមួយរយៈ មានចិត្តនឹករឭកមកដល់វត្តដែលធ្លាប់រស់នៅ ហើយមានបំណងចង់មកលេងវត្តវិញជាខ្លាំង។ រីឯការព្យាបាលជាលើកទីពីរនេះ បានធ្វើឱ្យព្រះនាងឈានទៅរកភាពធូរស្បើយ ពីព្រះរោគយ៉ាងច្រើន ហើយធ្វើអោយព្រះរាជា និងព្រះរាជិនីមានព្រះរាជហឫទ័យរីករាយជាពន់ពេក ។

While the head-monk was staying at the royal palace to cure Vorpheak's nasty illness, Thonn the crocodile, who was living under the royal residence port, felt homesick and really wanted to go back to the Wat. The head-monk's second attempt at healing sped up the recovery and thus gave much pleasure to the King and the Queen.

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



រូបទី ១១: ក្រពើ នេនធន នាំព្រះគ្រូមកវត្តនាគសែនវិញ
(Figure 11: Thonn brought the head-monk back to Neaksen wat)

មានថ្ងៃមួយបន្ទាប់ពីព្យាបាលព្រះនាងរួច ព្រះគ្រូក៏បានមកស្រង់ទឹកនៅឯមាត់ទន្លេ។ ដោយឃើញព្រះគ្រូកំពុងស្រង់ទឹកនៅក្បែរខ្លួន ក្រពើនេនធន ក៏ធ្វើជាមកបញ្ជិះព្រះគ្រូហែលលេងតែមួយសន្ទុះនៅក្នុងទន្លេ ដើម្បីឱ្យព្រះគ្រូបំភ្លេចនូវការនឿយហត់ព្រះកាយ ក្រោយពីការខិតខំព្យាបាល ព្រះរោគរបស់បុត្រីព្រះរាជា ។ ដោយមានចិត្តនឹករឭកដល់វត្ត និងមានឱកាសល្អផងនោះ ក្រពើនេនធនមិនបង្អង់ល្បឿនឡើយ ហើយព្យាយាមហែលតម្រង់មកកាន់វត្តនាគសែនវិញ សូម្បីតែព្រះគ្រូមិនទាំងដឹងខ្លួនជាមុនផង។

The day after the healing the head-monk took a bath in the river near the royal port. While seeing the head-monk taking a bath nearby, Thonn decided to take the head-monk on board and swim around a bit in order to help him release some stresses he might have after the curing of Vorpheak's illness. As Thonn wanted to go back to the Wat so badly, he saw this as the opportunity. Thonn the crocodile, with the head-monk on board, began to swim in the direction of Neaksen Wat, without the head-monk noticing at all.



រូបទី ១២: កាលដែលក្រពើ នេនធន ប្រទះនឹងក្រពើអ្នកតា
(Figure 12: Thonn fought with Neak Ta Crocodile)

*នៅតាមដងទន្លេមេគង្គ ក្រពើនេនធនបានជួបប្រទះជាមួយនឹងក្រពើ អ្នកតាដែលមាន ឫទ្ធិអំណាចខ្លាំងពូកែដែរ នៅឯភ្នំសុពណ៌កាលី [៦] ដែលស្ថិតនៅក្នុងស្រុកព្រែកប្រសព្វ ខេត្តក្រចេះសព្វថ្ងៃនេះ។ ក្រពើអ្នកតា នោះមានឈ្មោះថានាង ឱរ៉ៃ ជាក្រពើកំបុតកន្ទុយ។ នាងឱរ៉ៃបានឃើញក្រពើនេនធនក៏ចាប់ផ្តើមដេញតាមពីក្រោយ រីឯក្រពីនេនធនព្យាយាមគេចខ្លួនដោយមិនចង់តបតនោះទេ ។*

**On the way back in the Mekong river, Thonn encountered with another powerful Neak Ta (spirit) crocodile at Phnom Sopor Kaley[6], currently locates in Prek Prasob district of Kratie province. The Neak Ta crocodile was named Neang Orai, a tailless crocodile. Orai saw Thonn and ran after him to start a fight. Thonn tried to escape because he did not want any trouble.**

---

៦ ឯកសាររបស់លោក ជួប ឃាន ត្រង់ទំព័រទី ១១ បញ្ជាក់ថាភ្នំនេះមានឈ្មោះថា ភ្នំដីច្រាល់ លុះមកបច្ចុប្បន្ននេះគេហៅថាភ្នំសុពណ៌គីរី ឬសុពណ៌កាលី ស្ថិតនៅឃុំចំបក់ ស្រុកព្រែកប្រសព្វ ខេត្តក្រចេះ ។រីឯក្រពើអ្នកតានោះឈ្មោះថា អាយក្ស ។នៅត្រង់ទំព័រ ១៦ វិញបានបង្ហាញថា ក្រោយពីលេបព្រះនាង រួចហើយក៏បានជួបប្រទះនឹងក្រពើបឹងខាំគ្នាមួយយប់មួយថ្ងៃ នៅបឹងកាជោត គឺជាបឹងកេតបច្ចុប្បន្ន នៅក្នុងខេត្តកំពង់ចាម ។

6 In his book on page 11, Chuop Khean, indicates that the mountain was called Phnom Dei Chral, later called Phnom Sopor Kiri or Sopor Kaley locates currently in Chambak commune, Prek Prasob district, Kratie province. He also indicates The Neak Ta crocodile was called Ayeak. On page 16 he indicates that after swallowwing Vorpheak, Thonn encountered a fight for one day and one night with a crocodile in a lake, Boeng Kachoat or now called Boeng Ket in Kampong Cham province.



រូបទី ១៣: ស្ថានភាពភ្នំសុពណ៌កាលី ។ ថតនៅខែ ធ្នូ ២០០៥ ដោយ សុខាន់ណារ៉ូ ។
(Figure 13: The status of Phnom Sopor Kaley, photo by Sokhannaro in December 2005)

*ដោយក្រពើអ្នកតាដេញតាមប្រកិតពេក ក្រពើនេនធន ក៏ចង់សំដែងឫទ្ធិ ដែរនោះបានងាកក្រោយត្រៀមខ្លួនតបតវិញ ។ រំពេចនោះ ក្រពើនេនធន មិនដឹងថា នឹងត្រូវធ្វើយ៉ាងណាចំពោះព្រះគ្រូចៅអធិការដែល កំពុងតែជិះនៅលើខ្នងរបស់ខ្លួន ក្រៅពីសំរេចចិត្តលេបព្រះគ្រូទុកក្នុង ពោះនោះឡើយ តែរំពេចនោះ ក៏ទទួលបានការអនុញ្ញាតិពីព្រះគ្រូដែរ។ ក្រពើនេនធនបានលេបព្រះគ្រូភ្លាម ហើយក៏ចាប់ផ្តើមប្រយុទ្ធជាមួយ និងក្រពើអ្នកតានោះទៅ។*

The Neak Ta crocodile continued to follow closely so Thonn decided to face her as he wanted to show his power, too. Thonn did not know what to do with the head-monk on his back, so he decided to swallow the head-monk to protect him, but under the permission of the head-monk. Immediately after Thonn swallowed, he engaged in a fight with the Neak Ta crocodile.

ការប្រយុទ្ធគ្នាបានចំណាយអស់រយៈពេល ៧យប់៧ថ្ងៃ យ៉ាងសាហាវ ស្មើរតែរកចាញ់ឈ្នះមិនឃើញ ហើយបានធ្វើអោយមានការផ្អើលអស់មនុស្សម្នាមកចោមរោមមើល។ នៅទីបំផុតក្រពើអ្នកតា ក៏ត្រូវបានសម្លាប់ដោយក្រពើនេនធនខាំធ្លាយពោះ។ ដោយបានជ័យជំនះផង និងនឹកមកដល់វត្តផង ក្រពើនេនធន បានព្យាយាមហែលបន្តឆ្ពោះមកកាន់វត្តនាគសែន។ លុះមកដល់វត្ត ក៏បានខ្ជាក់ព្រះគ្រូចេញមក ទើបបានឃើញព្រះគ្រូសុគតបាត់ទៅហើយ[៧] ។

ប្រជាជន ព្រមទាំងព្រះសង្ឃគ្រប់អង្គនៅក្នុងវត្តមានការសោកស្តាយ ជាអនេកដោយបានបាត់បង់ព្រះគ្រូចៅអធិការដ៏ខ្លាំងពូកែទៅ។ ក្រពើនេនធនក៏មិននឹកស្មានថា ការធ្វើដូច្នេះនាំឱ្យព្រះគ្រូលាចាកលោកនេះនោះទេ តែមិនដឹងធ្វើរបៀបណា ព្រោះថាការប្រយុទ្ធគ្នាដោយទុកឱ្យ ព្រះគ្រូនៅលើខ្នងរបស់ខ្លួនអាចនឹងធ្លាក់ទឹកបាន ។ ក្រៅពីសោកសៅ ក្រពើនេនធនត្រូវបានមនុស្សម្នា និងព្រះសង្ឃបានត្លះតិះដៀលថាបានសម្លាប់ព្រះគ្រូដោយចេតនា ។

The fight lasted for seven days and seven nights. Both crocodiles showed considerable strength to continue to fight each other for this long, and this surprised many people. In the end, the Neak Ta crocodile was killed as Thonn bit her through the belly. Thonn could now continue to head towards the Neaksen Wat. On arrival, he regurgitated the head-monk and found him dead[7].

The monks and people of the Wat were very sorrowful because of the loss of their most respectful and strong guru. Thonn had never thought that swallowing the head monk would lead to his death. At the time he did not know what else to do as he thought that the head-monk might fall from his back during the fighting. Apart from feeling immense sorrow, Thonn was also badly reprimanded by the monks and the people as they thought he intentionally killed the head-monk.

---

[៧] មានការលើកឡើងត១គ្នាថា បើក្នុងរយៈពេលតិចជាង៧ថ្ងៃ ព្រះគ្រូចៅអធិការវត្ត អាចនៅមានព្រះជន្មនៅឡើយ ។

[7] It was believed that he might have stayed alive if it had been less than seven days.

ដោយមានការស្តីបន្ទោសយ៉ាងដំណំ ក្រពើនេនធនបានគិតពិចារណា អំពីដើមហេតុដែលនាំអោយព្រះគ្រូសុគត។ ទីបំផុតក៏បានយល់ឃើញថា មិនមែនជាកំហុសរបស់ខ្លួនទេ ហើយចាប់ផ្តើមចងកំហឹងជាខ្លាំងជាមួយនិងព្រះនាងវរភ័ក្ត្រ ព្រោះក្រពើនេនធនគិតថា បើព្រះគ្រូមិនបានទៅព្យាបាលព្រះរោគព្រះនាង ដោយធ្វើដំណើរចុះឡើងទេនោះ មិនបណ្តាលអោយព្រះគ្រូលាចាកលោកនេះឡើយ ហើយធនគិតថា ការប្រយុទ្ធគ្នាជាមួយនឹងក្រពើអ្នកតា ក៏ដោយសារការធ្វើដំណើរមកពីព្យាបាលជំងឺព្រះនាងដែរ។

ក្រោយពីបានគិតដូច្នោះមក ក្រពើនេនធនក៏បានហែលសំដៅមក រង់ចាំប៉ុនប៉ងជីវិតរបស់ព្រះនាងវរភ័ក្ត្រ។ លុះមកដល់ទីដែលធ្លាប់ចតរង់ចាំព្រះគ្រូនៅឯព្រះរាជដំណាក់ផែ ក្រពើនេនធនក៏បានលាក់ខ្លួន ពួនសំងំនៅក្រោមផែនោះ រង់ចាំឱកាសល្អដើម្បីលេបព្រះនាង។ ទោះជាយ៉ាងណាក្តី ពុំមានការបញ្ជាក់ច្បាស់ថា តើក្រពើនេនធនបានរង់ចាំក្នុងរយៈពេលប៉ុន្មាននិងស្គាល់ព្រះភ័ក្ត្រព្រះនាងដោយវិធីណានោះទេ។

Thonn did not believe that he deserved the blame that was being assigned to him. He started to think about the real causes for the death of the head-monk. In the end, Thonn believed that it was not his fault and he became very outraged with the daughter of the King. Thonn believed that if the head-monk did not spend time going to cure the King's daughter, he would have never passed away. He believed that the fight, and the reason he had to swallow the head-monk, was a result of the travel to cure the illness of Vorpheak.

After deciding this was the real cause, Thonn decided to take revenge and travelled all the way to Longvek in order to kill Preah Neang Vorpheak. When he reached the port where he waited for the head-monk during the daughter's healing day, Thonn secretly hid himself waiting for a good opportunity to swallow her. There is nothing to indicate how long Thonn waited under the port and how he came to know Preah Neang Vorpheak.



រូបទី ១៤: ព្រះនាងវរភ័ក្ត្រកំពុងក្រសាលទឹក
(Figure 14: Vorpheak took bath)

និយាយពីព្រះនាងវិញ កាលនោះហោរាបានទស្សន៍ទាយថា ព្រះនាងនឹងត្រូវអស់ព្រះជន្មនៅតាមទន្លេដោយសត្វក្រពើលេប។ ហេតុនេះហើយទើបព្រះរាជាមិនអនុញ្ញាតិឱ្យ ព្រះនាងទៅក្រសាលទឹកនៅតាមដងទន្លេឡើយ។ ប៉ុន្តែដោយព្រះនាងនៅតែទទូចអង្វរម្តងហើយម្តងទៀតថា ចង់ទៅក្រសាលទឹកលេងនៅក្នុងទន្លេ ទើបព្រះរាជាទ្រង់បញ្ជាឱ្យធ្វើរបងព័ទ្ធជុំវិញនៅត្រង់ព្រះរាជដំណាក់ផែ និងមានទាហានការពារនៅតាមដងទន្លេ ព្រមទាំងឱ្យភីលៀងជាច្រើននាក់ហែហមទៅជាមួយព្រះនាងដែរ។

It was predicted by the royal prophet that Vorpheak's life would be ended in the river by a crocodile. Therefore, The King decided she ought not to bathe in the river. Vorpheak kept demanding to bathe in the river, so The King ordered the entourage to fence off part of the river so that she could spend time swimming together with her maids (Srey Snams) in the river.



រូបទី ១៥: ក្រពើ នេនធន លេបព្រះនាងវរភ័ក្ត្រ
(Figure 15: Thoṇn crocodile swallowed Vorpheak)

តាមពិត ក្រពើនេនធនបានស្ថិតនៅក្នុងរបងដែលបានព័ទ្ធនោះរួចស្រេចទៅហើយ ដោយគ្មានអ្នកណាម្នាក់ដឹងឡើយ។ ថ្ងៃមួយ នៅពេលដែលព្រះនាងកំពុងតែក្រសាលទឹកលេង ជាមួយនិងស្រីស្នំមេនំមេនាង ព្រមទាំងមានរាជបរិពារកំពុងឈរការពារផងដែរ រំពេចនោះ ក្រពើនេនធន ក៏បានចេញពីក្រោមផែ ហើយសំដៅមកលេបព្រះនាងចូលទៅក្នុងពោះ ហើយក៏បានខាំហែករបងគេចខ្លួនបាត់ទៅ ។ ពួកស្រីស្នំ និងទាហានមិនអាចជួយអ្វីដល់ព្រះនាងឡើយ ក្រៅពីនាំគ្នាផ្អើលប្រញាប់រត់ទៅថ្វាយដំណឹងនេះដល់ព្រះរាជា។

Thonn was already under the port before they fenced in the areas with no-one noticing. One day when Vorpheak swam with her maids under the strict control of armed forces, Thonn suddenly rushed from his resting place and swallowed her. Thonn then broke the fence and escaped. All the Srey Snams and soldiers were frightened and hurriedly run to tell the King.



រូបទី ១៦: កាលដែលស្រីស្នំមេនំមេនាងចូលទូលព្រះរាជា
(Figure 16: The maids informed the King)

*ព្រះរាជាទ្រង់រន្ធត់ និងខ្ញាល់ជាខ្លាំងនៅពេលដែលឮហេតុការណ៍នេះ បន្ទាប់មកទ្រង់ក៏បានកោះហៅសេវកាមាត្យ ព្រមទាំងហោរា ឱ្យមកចូលគាល់ ហើយក៏ត្រាស់សួរទៅហោរាថា “តើធ្វើយ៉ាងដូចម្តេច ទើបអាចបានបុត្រីរបស់ព្រះអង្គមកវិញ ព្រមទាំងអាចសម្លាប់ក្រពើនោះ?” ហោរាក៏បានទូលទៅព្រះរាជាអំពីវិធីតែមួយដែលអាចដឹងថា ក្រពើនោះនៅឯណាគឺត្រូវបណ្តែតកន្ទោងវេទមន្ត[៨] តាមដងទន្លេបើកន្ទោង នោះអណ្តែតទៅឈប់នៅទីណា មានន័យថាក្រពើគឺពិតជានៅទីនោះ ហើយបើក្រពើផ្លាស់កន្លែង កន្ទោងក៏ប្តូរទីតាំងតាមដែរ។*

The King was very shocked and extremely angry. He gathered Sevakarmarts and prophet and asked how he could get his daughter back and kill the crocodile. The prophet said that the only way to know where the crocodile was to float the magic *kantoang*[8] *(cone-shaped banana leave.)* Wherever the kantoang stopped was where the crocodile stopped, and if the crocodile moved from place to another, the kantoang does, too.

[៨] ឯកសាររបស់លោកជួប ឃាន ត្រង់ទំព័រ ១៦ បញ្ជាក់ថាកន្ទោងខៀវ គឺជាកន្ទោងសីលវេទមន្តរបស់ពួកព្រាហ្មណ៍បុរោហិតប្រើ ចងដោយអំបោះ៧សរសៃសំរាប់ដេញតាមក្រពើនេទធន ។

[8] In is book on page 16, Chuop Khean, indicates that the Green Kantoang is a magic one tied to seven pieces of threads by Brahman in an attempt to capture Thonn the crocodile



រូបទី ១៧: កាលព្រះរាជាចាត់ពួកសេវកាមាត្យ ផ្សងកន្ទោងរកព្រះនាងវរភ័ក្រ្ក
(Figure 17: The King ordered Sevakamarts to use Kantoang to find Vorpheak)

ព្រះរាជាក៏ចេញរាជបញ្ជាអោយមន្ត្រី និង ពួកសេវកាមាត្យប្រើកន្ទោង វេទមន្តតាមហោរា ដើម្បីស្វែងរកព្រះនាងវរភ័ក្រ្ក។ ព្រះរាជា មន្ត្រី និង សេវកាមាត្យក៏ជិះលើទូកដ៏ស្អាតៗជង្ហែទៅតាមពីក្រោយកន្ទោងដើម្បីដឹងពីកន្លែងដែលព្រះនាង និងក្រពើធនធន[៩] នោះនៅ ។ កន្ទោងបានអណ្តែតពីរាជដំណាក់ផែនៃដងទន្លេសាប ហើយបន្តអណ្តែតបញ្ច្រាសទឹកហូរឡើងទៅតាមដងទន្លេមេគង្គ ។

**The King ordered the Sevakamarts to use the kantoang to find out the whereabouts of Vorpheak. The King, officials and entourage set out on nicely-decorated boats and followed the kantoang to know the whereabouts of Vorpheak and the crocodile[9]. The kantoang floated from royal residence port on the Tonle Sap River and then continued to float against the regular flowing direction of the Mekong River.**

[៩] នៅក្នុងបទសម្ភាសន៍នៃវិទ្យុអាស៊ីសេរីជាមួយលោកបណ្ឌិត កេង វ៉ាន់សាក់ អំពីព្រលឹងខ្មែរ ត្រង់ភាគទី ៤៣-៤៥ និង ៤៦ បានរៀបរាប់អំពីរឿងក្រពើធនធន ក្នុងសាច់រឿងផ្សេងៗពីគ្នាខ្លះ តែដោយឡែកនៅក្នុងបទសម្ភាសន៍នៅត្រង់ភាគទី ៤៧ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៥ បានបង្ហាញថា មានក្រពើមួយរស់នៅជាសិស្សជំនិត និងស្រឡាញ់លោកគ្រូខ្លាំងណាស់ ។ នាថ្ងៃមួយ ព្រះរាជាបានចាត់អោយគេមកទទួលលោកគ្រូដើម្បីមើលជំងឺរបស់បុត្រី តែដោយចាត់យូរពេក ក្រពើធនធនមកតាមរកគ្រូ ហើយក៏សងសឹកដោយគ្រាន់តែត្របាក់លេបបុត្រីស្តេចទុកក្នុងពោះ ។ រីឯទ័ពស្តេចដេញតាមរហូតដល់ទន្លេបិទ ក្រពើក៏បានគេចខ្លួនចូលតាមព្រែក តែគេបានដឹង គេដាក់ទ័ពនៅរង់ចាំនៅមាត់កំពង់ព្រែកនោះ ទើបគេហៅទីនោះថា កំពង់ចាំ ( ក្រោយមក គេបានហៅក្លាយមកជា កំពង់ចាម ដូចសព្វថ្ងៃនេះ តែមិនមែនសំដៅទៅលើជនជាតិចាម មកតាំងទីលំនៅត្រង់តំបន់នេះនោះទេ) ។

[9] In his interview with Radio Free Asia, Dr. Keng Vansak (series 43-46), told various stories related to Thonn the crocodile. However, in his interview of series 47, dated April 10, 2005, he mentioned that Thonn the crocodile, as the closest disciple, liked the guru (referring to the monk) so much that when the King invited the monk to cure the ailment of his daughter, Thonn was really frustrated waiting so long for guru's return that Thonn went in search of guru. As a vendetta, Thonn met the King's daughter and just swallowed her. The royal forces followed Thonn along the Mekong to a point called Tonle Bet. Thonn escaped through a tributary, but some of the royal forces were waiting at a juncture of that tributary, hence the area was called Kampong Jum (later it was called Kampong Cham, however, this interpretation of the name does not refer to an area where Muslim inhabitants resided)



រូបទី ១៨: ក្រពើ នេនធន ហែលចូលព្រែកឆ្លូង
(Figure 18: Thonn crocodile swam to Prek Chhlong tributary)



រូបទី ១៩: ស្ពានឆ្លូង និង ព្រែកឆ្លូងបច្ចុប្បន្ន
(Figure 19: The bridge and Prek Chhlong)

បន្ទាប់ពីបានលេបព្រះនាងរួចមក ក្រពើនេនធន បានគេចខ្លួនពីកន្លែង មួយទៅកន្លែងមួយតាម បណ្តោយដងទន្លេ ។ ជាចុងក្រោយ ដោយធ្វើ ដំណើរតាមកន្ទោងវេទមន្ត ពួកសេវកាមាត្យ និង មន្ត្រីទាំងឡាយនៅលើទូក ក៏បានទៅឃើញក្រពើ នេនធននៅព្រែកឆ្លូង (ជាដៃទន្លេធំមួយនៃទន្លេ មេគង្គត្រង់ស្រុកឆ្លូងខេត្តក្រចេះ)។ ក្រុមសេវកាមាត្យ ទាំងអស់បាន ព្យាយាមតាមចាប់ដោយប្រើឧបករណ៍ ផ្សេងៗជាច្រើន ប៉ុន្តែនៅតែចាប់មិនបាន ហើយក្រពើ នេនធន ក៏គេចខ្លួនចូលទៅទន្លេមេគង្គវិញ។

Since Thonn had swallowed Vorpheak, he had so far escaped the entourages and officials and traveled through the river. Finally, they found the crocodile at Prek Chhlong (one of the large tributaries of the Mekong in Chhlong district of Kratie) as directed by the kantoang. The Sevakamarts were disparately trying to catch the crocodile using different types of tools. However, Thonn had escaped to the Mekong again.



រូបទី ២០: ពួកសេវកាមាត្យបានចាររឫស្សីចាប់ក្រពើ នេនធន
(Figure 20: Sevakamarts used bamboo to block Thonn's way)

នៅខេត្តក្រចេះ នៅត្រង់ស្រុកក្រចេះ ប្រជាជនព្រមទាំងសេវកាមាត្យ ជាច្រើនបានព្យាយាមយកដើមឫស្សីបាំងកាត់ទទឹងទន្លេ ដើម្បីឃាំង មិនអោយក្រពើនេនធនអាចទៅណាបានឆ្ងាយទៀត ។ ហេតុដូចនេះហើយ ទើបទីកន្លែងដែលគេបានធ្វើរបាំងឃាំងផ្លូវក្រពើនេនធននោះ នៅពេលបច្ចុប្បន្ននេះត្រូវបានគេដាក់ឈ្មោះថា "ភូមិឫស្សីចារ" ដោយមានន័យថា ពួកសេវកាមាត្យ និងប្រជាជនយកឫស្សីធ្វើជារបងកាត់ ទន្លេដើម្បីស្ទាក់តាមចាប់ក្រពើនេនធន ប៉ុន្តែត្រូវបរាជ័យ។

At one point in Kratie district of kratie province. Sevakamarts and the people tried to use bamboo to block the crocodile from moving further. The place where the people did this is today known as "Russey Char village" which means 'people used bamboo to fence part of river to catch the crocodile, but failed'.



រូបទី ២១: ផ្សោតនៅព្រែកកាំពិរ ។ ថតកាលពីថ្ងៃទី ១៤ កក្កដា ២០០៧ ។
(Figure 21: The dolphins at Prek Kampir, photo on July 14, 2007)

គួររំលឹកថា មានទីកន្លែងជាច្រើនផ្សេងៗទៀត ដែលបានដាក់ឈ្មោះ ក្រោយពីប្រជាជនបាននាំគ្នាចាប់ក្រពើនេនធន ។ ក្រោយពេលគេចចូលមកទន្លេមេគង្គ ហើយឆ្លងកាត់អន្លង់ឫស្សីចារនេះ ក្រពើនេនធន បានបន្តមកព្រែកកាំពីរ ដែលសព្វថ្ងៃជាអន្លង់ផ្សោតដ៏សំខាន់ ។ ព្រែកកាំពីរត្រូវបានហៅឈ្មោះដូច្នេះ ពីព្រោះគេយករបារពីរកាំដើម្បីស្ទាក់ចាប់ក្រពើ ។

It should be noted that many places are named after areas where people tried to catch Thonn, and his subsequent escapes. Back in the Mekong, Thonn swam through the deep pool in Russey Char, then continued to Prek Kampir, where today there are very deep pools inhabited by dolphins. Kampir was named after two *robars* (small, long pieces of wood) which were used to block the crocodile's way.

ហើយបន្តមកទៀត ក្រពើនេនធន ក៏ហែលគេចខ្លួនចូលទៅក្នុងព្រែកមួយទៀត ពួកពលសេនាសេវកាមាត្យ ក៏នាំគ្នាយកថ្នោលមកចារជាចំណាររាំងមាត់ពាមព្រែកនោះ ទើបគេហៅថា ព្រែកចារថ្នោល ដល់សព្វថ្ងៃនេះ។ ឯក្រពើនេនធន បានហែលចូលជ្រៅទៅក្នុងព្រែក ដល់កន្លែងមួយហៅថា ពាមត្របែក ជាកន្លែងទាល់ទី ក្រពើនេនធន ក៏បានឡើងគោកវារកាត់មករកព្រែកមួយទៀត ដើម្បីទំលាក់ខ្លួនទៅរកទន្លេវិញ ។ នៅពេលនោះ ស្រាប់តែកន្ទោងបានមកជួបគ្នានៅទីនោះ គេហៅថា “វ៉ាក់ឬប៉ាក់” គ្នា ទើបព្រែកនេះមានឈ្មោះថា “អូរប៉ាក់” រហូតដល់សព្វថ្ងៃនេះ ។

Thonn then escaped to another tributary, the Sevakamarts used long poles (*Thnoal)* to block Thonn's way at the juncture of the small tributary and the Mekong and therefore, the small tributary is called Prek Char Thnoal. Thonn had gone further along the tributary until its end point, then took a sharp turn by crawling on land in order to find another tributary before moving back to the Mekong. In another tributary on the way back to the Mekong, Thonn abruptly encountered the kantoang, an area now called "Vak or Pak, meaning a sudden and surprise encountering" and this tributary is today still called "O'pak".



រូបទី ២២: ស្ថានភាពទន្លេស្រែពក នៅត្រង់ភូមិស្រែឈូក ស្រុកលំផាត់ ថតនៅថ្ងៃទី ៦ កក្កដា ២០០៧
(Figure 22: Sre Pok River at Sre Chhouk village, Lumphat district, photo on July 6, 2007)

*តាំងពីពេលនោះមក កន្ទោងបានបន្តដំណើរតាមក្រពើ នៅលើផ្ទៃទន្លេមេគង្គបន្តទៀត រីឯព្រះរាជានាម៉ឺនសព្វមុខមន្ត្រី សេវកាមាត្យ និងហោរាក៏ធ្វើដំណើរតាមពីក្រោយកន្ទោងជាហូរហែ ដើម្បីរកឱកាសល្អចាប់ក្រពើអោយបាន ។ ក្រពើនេនធនបានមកដល់ទឹកដីនៃខេត្ត ស្ទឹងត្រែង ហើយក៏បានបន្តគេចខ្លួនតាមដងទន្លេស្រែពក ដែលជាដៃទន្លេដ៏ធំមួយនៃដៃទន្លេមេគង្គដទៃទៀត ដែលទន្លេនេះតភ្ជាប់មកកាន់ខេត្តរតនគីរី ។ នៅក្នុងទន្លេស្រែពក មានអន្លង់ជ្រៅច្រើនកន្លែងដែលមានទំហំ និងជម្រៅខុសៗគ្នា ជាជំរកដ៏ល្អសំរាប់មច្ឆាជាតិ និងសត្វមានជីវិតឯទៀត។*

The kantoang continued to move after the crocodile on the Mekong. The King, the officials and royal prophet were also traveling after the kantoang to observe closely where the crocodile could be caught. Thonn continued to escape and reached Steung Treng province. He continued along Sre Pok River, one of the largest tributaries of the Mekong connecting with Ratanakiri province. In fact, in the Sre Pok River there are many deep water pools, varies in size and depth, provide an excellent habitat for fisheries and other living species.

HUN SEN LIBRARY
R.U.P.P.



រូបទី ២២: ស្ថានភាពទន្លេស្រែពក នៅត្រង់ភូមិស្រែឈូក ស្រុកលំផាត់ ថតនៅថ្ងៃទី ៦ កក្កដា ២០០៧
(Figure 22: Sre Pok River at Sre Chhouk village, Lumphat district, photo on July 6, 2007)

*តាំងពីពេលនោះមក កន្ទោងបានបន្តដំណើរតាមក្រពើ នៅលើផ្ទៃទន្លេមេគង្គបន្តទៀត រីឯព្រះរាជានាម៉ឺនសព្វមុខមន្ត្រី សេវកាមាត្យ និងហោរាក៏ធ្វើដំណើរតាមពីក្រោយកន្ទោងជាហូរហែ ដើម្បីរកឱកាសល្អចាប់ក្រពើអោយបាន ។ ក្រពើនេនធនបានមកដល់ទឹកដីនៃខេត្ត ស្ទឹងត្រែង ហើយក៏បានបន្តគេចខ្លួនតាមដងទន្លេស្រែពក ដែលជាដៃទន្លេដ៏ធំមួយនៃដៃទន្លេមេគង្គដទៃទៀត ដែលទន្លេនេះតភ្ជាប់មកកាន់ខេត្តរតនគិរី ។ នៅក្នុងទន្លេស្រែពកមានអន្លង់ជ្រៅច្រើនកន្លែងដែលមានទំហំ និងជម្រៅខុសៗគ្នា ជាជំរកដ៏ល្អសំរាប់មច្ឆាជាតិ និងសត្វមានជីវិតឯទៀត។*

The kantoang continued to move after the crocodile on the Mekong. The King, the officials and royal prophet were also traveling after the kantoang to observe closely where the crocodile could be caught. Thonn continued to escape and reached Steung Treng province. He continued along Sre Pok River, one of the largest tributaries of the Mekong connecting with Ratanakiri province. In fact, in the Sre Pok River there are many deep water pools, varies in size and depth, provide an excellent habitat for fisheries and other living species.

បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.

នៅតាមដងទន្លេស្រែពក[១០] ក្រពើនេនធន បានមកពួនសំងំនៅត្រង់អន្លង់ផ្តិល នៅក្នុងស្រុកកូនមុំ នៃខេត្តរតនគិរី ។ ការតាមចាប់នេះ មានទាំងទូកសំពៅ និងមានរទេះទៀតផង រហូតដល់មានការបាក់រទេះនៅចន្លោះឃុំស្រែអង្គ្រង ស្រុកកូនមុំ និងភូមិស្រែពកនៃឃុំសេរី មង្គល ទើបគេអោយឈ្មោះនៅតំបន់នោះសព្វថ្ងៃថា នាងស្កាបាក់រទេះ លុះបន្តដំណើរមកទៀត ក៏សំពៅព្រះរាជានៅជាប់គៀងត្រង់ចំណុចមួយត្រង់ឃុំសេរីមង្គល ដែរទើបគេដាក់ឈ្មោះទីនោះថា កោះសំពៅ ដែលជាកោះមួយនៅកណ្តាល ទន្លេស្រែពកសព្វថ្ងៃ។ នៅលើកោះសំពៅនេះ ពុំមានមនុស្សរស់នៅទេ តែគេឃើញមានដើមស្វាយដុះនៅលើនោះខ្លះដែរ ។

Along the Sre Pok River[10], Thonn quietly hid in Anlong Ptel in Kaun Mom district of Rattanakiri. In an attempt to seize Thonn, boats called Sampov (sailing junk) and carts were used. One of the carts was broken between Sre Angkrong commune of Kaun Mon district and Sre Pok village of Serey Mungkol commune and so the broken cart area is now called Neang Skar Bak Rotes. Further up the river, the Sampov was stuck in Serey Mungkol commune and it is now called Koh Sampov or Sailing Junk island, an island located right in the middle of the river. There are no inhabitants on the island but there are some mango trees on it.

---

[១០]នៅក្នុងប្រជុំរឿងព្រេងខ្មែរ ភាគទី ៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០១ ត្រង់ទំព័រ ១៨៧ បង្ហាញថា ក្រពើអាធន បានទៅតាមទន្លេមេគង្គរហូតដល់ស្រុកខោន (នៅជាប់ព្រំដែនកម្ពុជា-ឡាវ) ហើយនៅសំងំទីនោះ ២-៣ថ្ងៃ ទើបហែលចុះមកវិញ ហើយនៅទីបំផុត អាធន ក៏ត្រូវបានចាប់យកមកប្រហារជីវិតបាននៅឯព្រែកឆ្លូង ដោយការបន់ស្រន់អោយមេមត់ជួយ ដោយការព្រមថ្វាយស្បែកក្រពើ ។

[10] The Collection of Khmer Folklores, 5th series, of Buddhist Institute 2001, page 187, illustrates that A-Thonn escaped through the Mekong until Khoan area (Cambodian-Laos border) and stayed secretely there for 2-3 days, he then swam back down the river. Finally, A-Thonn was captured and killed at Prek Chhlong with the help of Memot (magician) who was promised to offe the crocodile skin after capture.



រូបទី ២៣: បឹងលំផាត់សព្វថ្ងៃ
(Figure 23: The current status of Lumphat Lake)

ក្រពើនេនធន បានបន្តគេចខ្លួនមកដល់ទឹរូមស្រុកលំផាត់សព្វថ្ងៃហើយ បានងាកខ្លួនឡើងគោកសំដៅទៅបឹងលំផាត់។ បឹងនេះមានបណ្តោយប្រហែល៣០០ម៉ែត្រ និងទទឹងប្រហែល៦០ម៉ែត្រ ដែលស្ថិតនៅជិតទន្លេ ស្រែពកប្រហែល១០០ម៉ែត្រ។ ក្រពើនេនធន បានសំងំនៅក្នុងបឹងនោះ ព្រោះខ្លួនធំពេក មិនអាចអោយខ្នងរបស់ខ្លួនលិចទៅក្នុងទឹកបាន ដោយសារតែដឹងថា ត្រូវខ្យល់ផាត់ចំខ្នងនោរហើយនៅឡើយ ទើបគេចចេញពីបឹងនេះទៀត។ បឹងនេះត្រូវបានហៅតាមភាសាឡាវថា លំផាត់ ដែលមានន័យថា “ ខ្យល់បក់ ឬខ្យល់ផាត់” ដោយមាននិគមជនឡាវ រស់នៅទីនោះតាំងពីអតីតកាលមក ។

Thonn moved on to the Lumphat district and then went up land toward Lumphat Lake. This lake is about 300 meters long and 60 meters wide, about 100 meters away from Srek Pok River. Due to Thonn's large body he had difficulty hiding in the lake, he could feel the wind blowing over his back (indicating he was exposed to the view of his captors). Thonn decided to escape from the lake. The lake then was subsequently called Lumphat in Laos meaning "wind blowing".



រូបទី ២៤: វត្តអារញ្ញារាមដែលស្ថិតនៅក្នុងទីរួមស្រុកលំផាត់បច្ចុប្បន្ននេះ
(Figure 24: Wat Aranharam in Lumphat district town)

បន្តពីបឹងលំផាត់ ពុំមានអ្នកណាអាចរៀបរាប់បានអំពីលំដាប់លំដោយ ទីកន្លែងដែលក្រពើនេនធនបានទៅដល់នោះទេ គ្រាន់តែដឹងថាក្រពើ នេនធនចូលតាមអូរទទឹងដែលនៅចន្លោះភូមិនាងដី និងភូមិសាមខា (ជាភាសាឡាវមានន័យថា ជើងបី ឬ មុំចង្ក្រាន) ស្ថិតនៅឃុំជ័យឧត្តម ស្រុកលំផាត់។ ក្រពើនេនធនបានឡើងគោក ទើបមានការអូសទូកតាមពីក្រោយ ហើយមានជាប់ឈ្មោះសព្វថ្ងៃថា វាលអូសទូក នៅក្នុងឃុំកាឡែង ស្រុកលំផាត់ ។

**From Lumphat, no-one knows where Thonn had moved, but it is thought that Thonn had gone through O'Toteung, the stream located between Neang Dei village and Samkhar village (three legs in Lao) in Chey Ouddom commune of Lumphat district. Thonn went up land and in order to follow him, his followers had to pull their boats overland, this is why there is an area called Os Touk field or valley, located in Kaleng commune of Lumphat district.**



រូបទី ២៥: បឹងលំកុដិ នាពេលបច្ចុប្បន្ននេះ
(Figure 25. the current status of Lumkod Lake)



រូបទី ២៦: បឹងយក្សឡោម នាពេលបច្ចុប្បន្ននេះ
(Figure 26: the current status of Yeak Loam Lake)
http://www.pbase.com/brambos/image/6798973

*ក្រពើនេនធន បានទៅដល់បឹងយក្សឡោម នៅជិតទីរួមខេត្តរតនគិរី តែមិនដឹងជាមានមូលហេតុអ្វីបានចេញពីទីនោះទៅតាមអូរជីប ជាអូរមួយឆ្លងកាត់ភូមិជាច្រើន ក្នុងនោះមានភូមិ ណាខាម (តាមភាសាទំពួន មានន័យថាស្រែខាម) នៃឃុំសេដាផ្តោះ ទៅកាន់បឹងលំកុដិជាបឹងមួយធំជាងបឹងយក្សឡោម ក្នុងចំងាយប្រហែល ៣០០ម៉ែត្រពីសាលាឃុំសេដា នៃស្រុកលំផាត់ ។ ទៅដល់ទីនោះក៏មិនអាចសំងំនៅបានទៀត ក្រពើនេនធនបន្តគេចខ្លួនទៅដល់បឹងចុងក្រោយមានឈ្មោះថា បឹងលំប៉ស់ ជាបឹងមួយដែលមានរាងទ្រវែង និងជ្រៅទៀតផង។ បឹងនេះស្ថិតនៅក្នុងឃុំលំជ័រ នៃស្រុកអូរយ៉ាដាវ ខេត្តរតនគិរី[១១] ។*

**Thonn had reached Yeak Loam Lake near Ratanakiri provincial town but for some reason he could not stay in that lake. So Thonn moved along O'Chib, a stream flowing across many villages, one of which is Nakham village (it means Kham rice field in Tumpuon dialect) of Seda commune. Thonn then reached Lumkod, a larger lake than Yeak Loam. Again, Thonn could not stay in this lake and so continued to a final lake called Lumpors, a deep and long lake. This final lake is located in Lumchor commune, O'yadav district of Ratanakiri[11] province.**

[១១] វចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ចុះថ្ងៃទី ១០ ធ្នូ ១៩៦៧ (ព.ស. ២៥១១) ត្រង់ទំព័រ ៦០៦ បង្ហាញថា រតនគិរី គឺជាឈ្មោះខេត្តមួយនៃកម្ពុជរដ្ឋ បំបែកចេញពីខេត្តស្ទឹងត្រែង ហើយតែងតាំងឡើងពីឆ្នាំ ១៩៥៩ (ព្រះរាជក្រមលេខ ២៩៨-នស ចុះថ្ងៃទី ១៧ កុម្ភៈ ១៩៥៩) ។

[11] Khmer Dictionary of Supreme Patriarch Chuon Nath Choatanheannoa, Published by Buddhist Institute, December 10, 1967 (B.E. 2511), page 606, indicates that Ratanakiri is the name of Cambodia's province separated from Steung Treng province since 1959 (Reach Krom 298-ns dated February 17, 1959).



រូបទី ២៧: ពួកសេវកាមាត្យនាំគ្នាមកព័ទ្ធចាប់ក្រពើ ធនធន បាននៅលំផាត់
(Figure 27: Sevakamarts caught Thonn at Lumphat)

នៅទីបំផុតក្រពើធនធន ក៏មិនអាចបន្តគេចទៅបានក្រោយពីព្យាយាម គេចខ្លួនក្នុងរយៈចំងាយដ៏ឆ្ងាយឆ្ងាយ ទាំងលើគោកផងនិងនៅក្នុងទឹកផង។ ក្រពើធនធនបានលាក់ខ្លួនសំងំនៅក្នុងបឹងលំប៉ស់។ ដោយបានដឹងថា ក្រពើធនធននៅក្នុងបឹងជ្រៅនេះពិតប្រាកដហើយ ព្រះរាជា ទ្រង់ត្រាស់បង្គាប់ឱ្យអ្នកមានថ្វីដៃខាងមុជទឹក ដើម្បីដេញក្រពើឱ្យចេញពីបឹងនិងមានអ្នករង់ចាំចាប់ ។ នៅក្នុងពេលដែលមានការមុជដេញ ក្រពើក៏បានលោតឡើងមកលើហាមាត់ ហើយពួកសេវកាមាត្យក៏បាន បោះផ្លែដូងមួយចំនួនចូលទៅក្នុងមាត់ក្រពើ ហើយក្រពើបានខាំផ្លែដូងជាប់និងធ្មេញដែលបណ្ដាលអោយខាំអ្វីទៀតមិនបាន ហើយអ្នកចាប់ ក៏បានប្រើឧបករណ៍ជាច្រើនប្រភេទដើម្បីចាប់ហើយចាប់បានទាំងនៅរស់នៅឡើយ[១២] ។

Thonn was finally exhausted after traveling a very long distance to escape both on water and land. Thonn ended up hiding himself in Lumpors, a deep and long lake. When realizing that Thonn laid in this Lake, the King ordered Sevakamarts to dive into deep water to chase out the crocodile, while many others were ready to catch him when he rose to the surface. When chasing Thonn out of the Lake, Thonn appeared on water's surface with his mouth open. The Sevakamarts threw some coconuts into his mouth to disable his ability to bite and then caught him alive[12].

[១២] អ្នកខ្លះបាននិយាយថា គេបានប្រើខ្សែសិម្មាដើម្បីហៅក្រពើអោយឡើងមកលើផ្ទៃទឹកដើម្បីចាប់ ។

[12] Some people mentioned about the use of magic threa[d] to bring the crocodile up the water's surface.



រូបទី ២៨: ហោរាទាយគន់គូរមើលថា តើព្រះនាងនៅរស់ ឬស្លាប់

(Figure 28: The royal prophet predicted if she were dead or alive

ពួកសេវកាមាត្យបាននាំគ្នាយកខ្សែចងរិតយ៉ាងតឹង ដើម្បីនាំយកក្រពើ នេនធន មកលើគោកដើម្បីរង់ចាំព្រះរាជបញ្ជាបន្ត។ នៅក្នុងគ្រានោះ ហោរាបានទូលថ្វាយទៅព្រះរាជាថា ព្រះនាងអាចនៅមានព្រះជន្មនៅឡើយបើសិនជាទុកអោយក្រពើ នេនធន ក្អួតព្រះនាងចេញមកក្រៅ។ ប៉ុន្តែដោយទឹកចិត្តអាណិតអាសូរ និងចង់ជួបបុត្រីភ្លាមៗនោះ ព្រះរាជាមិនព្រមរង់ចាំតាមការទស្សន៍ទាយរបស់ហោរាទេ ហើយក៏មិនសង្ឃឹមថា បុត្រីនៅមានព្រះជន្មដែរ ព្រោះនៅក្នុងពោះក្រពើអស់រយៈពេលយូរថ្ងៃមកហើយ ។

**The Sevakamarts tied up the crocodile with rope very tightly and brought him upland to wait for the royal order. At that moment, the prophet told the king that his daughter could still be alive if the crocodile were allowed to regurgitate her. The King was extremely upset and disparately wanting to see his daughter. He took no notice of the prediction and he had no hope that his daughter remained alive.**



រូបទី ២៩: ព្រះរាជាចាត់សេវកាមាត្យអោយវះពោះក្រពើ នេនធន
(Figure 29: The King ordered Sevakamarts to cut open Thonn's belly)

ទន្ទឹមនិងមានការអាណិតអាសូរចំពោះបុត្រីជាពន់ពេកនោះ ព្រះរាជាក៏ខ្វាល់ខ្វាំងណាស់ ទើបបានចេញបញ្ជាអោយសេវកាមាត្យវះពោះក្រពើនេនធន ដើម្បីយកព្រះនាងចេញមកវិញ។ រំពេចនោះសេវកាមាត្យក៏ ធ្វើតាមការបញ្ជារបស់ព្រះអង្គ ប៉ុន្តែគួរអោយសោកស្តាយណាស់ព្រោះពួកគេបានឃើញត្រឹមតែសាកសពរបស់ព្រះនាងប៉ុណ្ណោះ។ នៅពេលដែលវះបានភ្លាមៗនោះ ព្រះរាជា និង សេវកាមាត្យបានប៉ះរាងកាយរបស់ព្រះនាង ហើយថាសាច់ព្រះនាងក្តៅនៅឡើយ[១៣] ។

The King was outraged and so he ordered that the crocodile belly be cut open to remove his daughter. As soon as the Sevakamarts did that, they become extremely regretful as they saw the daughter had already passed away. As they were removing Vorpheak's body, the King and the Sevakamarts realized the body was still warm[13].

[១៣] នៅក្នុងបទសម្ភាសន៍នៃវិទ្យុអាស៊ីសេរីជាមួយលោកបណ្ឌិត កេង វ៉ាន់សាក់ អំពីព្រលឹងខ្មែរ ត្រង់ភាគទី ៤៧ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៥ បានបន្តថា ក្រោយពីគេចាប់ក្រពើនោះបាន គេបានវះពោះ ហើយសម្លាប់ក្រពើនោះចោល តែបុត្រីព្រះរាជា នៅក្តៅខ្លួន និងមានព្រះជន្មនៅឡើយ ។ លុះពេលដឹងខ្លួនឡើង ព្រះនាងបានសួររកក្រពើ តែដោយដឹងថា ក្រពើនោះត្រូវគេសម្លាប់ ព្រះនាងបានដាច់ខ្យល់អស់ព្រះជន្ម ទៅតាមក្រពើនោះដែរ ។ ព្រះរាជាបានឱ្យគេកសាងវត្ត សំរាប់ធ្វើបុណ្យបញ្ជូនព្រលឹងព្រះរាជបុត្រី ដែលគេហៅថា វត្តសសរ១០១ ដោយគេបានយកស្ត្រីមានផ្ទៃពោះទៅកប់នៅតាមជើងសសរព្រះវិហារនីមួយៗ ដើម្បីអោយទៅជាព្រាយ សំរាប់ថែរក្សាព្រះរាជបុត្រី ក៏ដូចជាការពារវត្តផងដែរ (ទោះជាយ៉ាងណាក្តី ក្នុងការនិទានរឿងនេះ លោកមិនបានបញ្ជាក់ប្រាប់ពីទីតាំងពិតនៃវត្តនោះទេ) ។

[13] In his interview with Radio Free Asia, Dr. Keng Vansak, in series 47, dated April 10, 2005, continued by saying that after Thonn was captured, his belly was cut open, and the King's daughter was found breathing. Once fully conscious she looked eagerly for the crocodile, upon learning that the crocodile had been killed, she became distraught and breathless. The King ordered the building of a 101-Pillar Vihear for his daughter. He also ordered that pregnant women be murdered to place in the foundation of each pillar so as the spirits would care for both the daughter's soul and Preah Vihear (the location was not mentioned by the interviewee).



រូបទី ៣០: កាលព្រះរាជាធ្វើពិធីបូជាព្រះសពព្រះនាងវរភ័ក្រ្ត នៅលំផាត់
(Figure 30: The King cremated the body of Vorpheak at Lumphat)

ការបូជាព្រះសពក៏ត្រូវបានប្រារព្ធធ្វើនៅលំផាត់[១៤] ក្រោមការចូលរួមមរណៈទុក្ខក្រៀមក្រំពីសំណាក់រាជវង្សានុវង្សសព នាម៉ឺនសព្វមុខមន្ត្រី និងមនុស្សម្នា នៅតំបន់នោះយ៉ាងច្រើន ។ មុននឹងបូជាមានការរៀបចំព្រះមេរុបានល្អត្រឹមត្រូវសមតាមព្រះកិត្តិនាមព្រះមហាក្សត្រ និងបាននិមន្តព្រះសង្ឃនៅតំបន់នោះ សូត្រធម៌ក្នុងពេលបូជាព្រះសព។ ក្នុងពិធីនោះ ព្រះរាជាក៏សំរេចចិត្តយកស្បែកក្រពើមកដាក់ឆ្លាងធ្វើជាទង់ដើម្បីបញ្ជាក់ថា ព្រះនាងបានអស់ព្រះជន្មដោយសារតែសត្វក្រពើ ។

It was decided Vorpheak would be cremated at Lumphat[14]. Many people were in attendance during the cremation ceremony, all were very sad at the loss of Vorpheak's life. Before the cremation, the cremating tower was beautifully prepared and decorated to the royal standards, and the King invited Monks to preside over the cremation ceremony. For the ceremony, The King decided to use the crocodile skin to make a funeral banner signaling that his daughter passed away because of the crocodile.

[១៤] នៅក្នុងប្រជុំរឿងព្រេងខ្មែរ ភាគទី ៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០១ ត្រង់ទំព័រ ១៨៨ បានបញ្ជាក់ថា ព្រះសពរបស់ព្រះរាជបុត្រី ត្រូវបានបូជាព្រះភ្លើងនៅស្រុកសំបូរ ហើយបញ្ចុះព្រះធាតុក្នុងព្រះចេតិយមួយនៅក្នុងវត្តសំបូរ ។

[14] The Collection of Khmer Folklores, 5th series, of Buddhist Institute 2001, page 188 indicates that the daughter's body was cremated at Sambor district and enshrined her remains in a stupa in Wat Sambor.



រូបទី ៣០: កាលព្រះរាជាធ្វើពិធីបូជាព្រះសពព្រះនាងវរភ័ក្រ្ត នៅលំផាត់
(Figure 30: The King cremated the body of Vorpheak at Lumphat)

ការបូជាព្រះសពក៏ត្រូវបានប្រារព្ធធ្វើនៅលំផាត់[១៤] ក្រោមការចូលរួមមរណៈទុក្ខក្រៀមក្រំពីសំណាក់រាជវង្សានុវង្សសព នាម៉ឺនសព្វមុខមន្ត្រី និងមនុស្សម្នា នៅតំបន់នោះយ៉ាងច្រើន ។ មុននឹងបូជាមានការរៀបចំព្រះមេរុបានល្អត្រឹមត្រូវសមតាមព្រះកិត្តិនាមព្រះមហាក្សត្រ និងបាននិមន្តព្រះសង្ឃនៅតំបន់នោះ សូត្រធម៌ក្នុងពេលបូជាព្រះសព។ ក្នុងពិធីនោះ ព្រះរាជាក៏សំរេចចិត្តយកស្បែកក្រពើមកដាក់ភ្ជាប់ធ្វើជាទង់ដើម្បីបញ្ជាក់ថា ព្រះនាងបានអស់ព្រះជន្មដោយសារតែសត្វក្រពើ ។

It was decided Vorpheak would be cremated at Lumphat[14]. Many people were in attendance during the cremation ceremony, all were very sad at the loss of Vorpheak's life. Before the cremation, the cremating tower was beautifully prepared and decorated to the royal standards, and the King invited Monks to preside over the cremation ceremony. For the ceremony, The King decided to use the crocodile skin to make a funeral banner signaling that his daughter passed away because of the crocodile.

[១៤] នៅក្នុងប្រជុំរឿងព្រេងខ្មែរ ភាគទី ៥ របស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ២០០១ ត្រង់ទំព័រ ១៨៨ បានបញ្ជាក់ថា ព្រះសពរបស់ព្រះរាជបុត្រី ត្រូវបានបូជាព្រះភ្លើងនៅស្រុកសំបូរ ហើយបញ្ចុះព្រះធាតុក្នុងព្រះចេតិយមួយនៅក្នុងវត្តសំបូរ ។

[14] The Collection of Khmer Folklores, 5th series, of Buddhist Institute 2001, page 188 indicates that the daughter's body was cremated at Sambor district and enshrined her remains in a stupa in Wat Sambor.

ថ្វីបើការប្រើប្រាស់ទង់ក្រពើនៅក្នុងពិធីបុណ្យសព មានតាំងពីសម័យពុទ្ធកាល[១៥]មកក៏ដោយ តែសក្ខីភាពដែលបានកើតមានឡើងនៅក្នុងរជ្ជកាលព្រះអង្គចន្ទរាជាដែលយកស្បែកក្រពើដាក់ឆ្កាង រឹតតែជំរុញឱ្យទម្លាប់នៃការប្រើទង់ក្រពើ[១៦]ក្នុងពិធីបុណ្យសព កាន់តែមានការអនុវត្តន៍ជាបន្តបន្ទាប់រហូតមកដល់បច្ចុប្បន្ននេះ តែគេបានប្រើក្រណាត់ដោយធ្វើទ្រង់ទ្រាយដូចស្បែកក្រពើដាក់ឆ្កាងដូច្នោះដែរ ហើយទម្លាប់នេះកាន់តែមានភាពជិតដាមជាប់នៅក្នុងសង្គមខ្មែរយើងថែមទៀត។

ក្រោយពីបានបូជាព្រះសព្វរួចរាល់ហើយ ការផ្សងកន្ទោងជដែលត្រូវបានរៀបចំឡើង ក្នុងគោលបំណងទៅរកទីតាំងដែលសមស្របសំរាប់តម្កល់ព្រះអដ្ឋិធាតុរបស់ព្រះនាង។ គេមានជំនឿថាការធ្វើដូច្នោះនឹងនាំមកនូវសេចក្តីសុខ សំរាប់ទាំងព្រះនាងដែលបានទៅកាន់បរលោក និងអោយមានភាពសុខដុមរមនា ដល់អ្នកដែលមានជីវិតរស់នៅផងដែរ។

---

[១៥] លោកតា សោ ម៉ុន ជាប្រធានគណៈកម្មការវត្តព្រះវិហារធំសសរ១០០ កាលពីថ្ងៃទី ១៧ សីហា ២០០៧ បញ្ជាក់ថាទង់ក្រពើទាក់ទងទៅនឹងរឿងដូចតទៅ: មាននាគមួយបានកាឡាខ្លួនជាមនុស្ស និងបានមកថ្វាយបង្គំព្រះពុទ្ធសមណគោតម ដើម្បីសុំខ្លួនបួសជាព្រះសង្ឃ ។ ដោយឃើញទឹកចិត្តជ្រះថ្លា ព្រះពុទ្ធក៏បានយល់ព្រម បំបួស ។ នាថ្ងៃមួយ មានព្រះសង្ឃមួយអង្គទៀតបានទៅរកព្រះសង្ឃអង្គនោះ ដោយគោះទ្វារបន្ទប់នៃកុដិ ហើយបានបើកឡើង ស្រាប់តែឃើញសត្វនាគឆ្វាយវង្វេលនៅក្នុងបន្ទប់ទៅវិញ ។ ដំណឹងនេះក៏បាន លេចឮដល់ព្រះពុទ្ធ ទើបតាំងពីពេលនោះមក ព្រះពុទ្ធបានដាក់បញ្ញត្តមិនឱ្យសត្វតិរច្ឆានមកបួសជាព្រះសង្ឃបានទេ ។ មិនយូរប៉ុន្មានក៏ស្រាប់តែមានក្រពើ មួយក្បាល មកសុំព្រះពុទ្ធបួសជាសង្ឃដែរ តែដោយមានព្រះបញ្ញត្តទើបមិនអាចធ្វើបានទេ ។ ក្រពើក៏នៅតែទទូចថា នៅពេលដែលខ្លួន ស្លាប់ សុំអោយព្រះពុទ្ធយកស្បែកមកធ្វើជា ទង់ផង ។ ដោយឃើញទឹកចិត្តជ្រះថ្លា ព្រះពុទ្ធក៏បានយល់ព្រមតាម ។ តាំងពីពេលនោះទើបមានការប្រើប្រាស់ទង់ក្រពើជារហូតមក ។

[១៦] នៅក្នុងបទសម្ភាសន៍នៃវិទ្យុអាស៊ីសេរីជាមួយលោកបណ្ឌិត កេង វ៉ាន់សាក់ អំពីព្រលឹងខ្មែរ ចាប់ពីភាគទី ៤៣-៤៧ នៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៥ បានលើកឡើងថា ទង់ក្រពើ គេអាចហៅថា ទង់រលក ( មកពីរលកទឹក ) ឬទង់ព្រលឹង ។ ទង់នេះត្រូវគេប្រើនៅក្នុង ពិធីបុណ្យសព ពិធីពូនភ្នំខ្សាច់ និង ចងដាក់នៅតាមវត្តជាដើម ជាជំនឿ ឬជាតំណាងភាវៈដ៏ល្អរបស់ខ្មែរតាំងពីបុរាណកាលមក ។ ភាវៈល្អនៃ ជំនឿរបស់ខ្មែរយើងគឺ នាងគង្ហីង = មេ និង ក្រពើ = បា ដែលនៅជាមួយគ្នាជានិច្ចគឺ មេបា ឬ នាងគង្ហីងគឺជាធាតុដី រីឯក្រពើជាធាតុទឹក ។

**Though the use of crocodile banner for funerals has been around since Buddha's time[15], the happening in Preah Ang Chan Reachea's era reinforced the practices[16] in Khmer society and has been maintained until the present time. However, the crocodile skin is not used, but the cloth is intentionally made into the shape of a crocodile.**

**After the funeral, the same kantoang was used in order to identify a suitable place where the remains of The King's daughter be enshrined. It was believed this would bring tranquility for Vorpheak's soul to rest in heaven and it would also bring happiness for her loved ones who were still living.**

[15] On August 17, 2007 Mr. Soa Monn, the head of the committee of 100-pillar Preah Vihear Thom, offered a more detailed account of the crocodile banner as follows:
A dragon disguised as a person approached Buddha in order to be ordained. His good will convinced Buddha to ordain him. One day, another monk visited the room of the ordained monk, after knocking and opening the door, he suddenly saw a dragon instead of a monk. As soon as Buddha was informed about this, he prescribed that no animals were to ever be ordained. Later, a crocodile also approached Buddha to be ordained, but this not possible due to the previous prescription. Nevertheless, the crocodile insisted that when it died, its skin may be used as a banner. Buddha agreed due to the crocodile's conviction. The crocodile banner has been maintained ever since.

[16] In his interview with Radio Free Asia, Dr. Keng Vansak, series 43-47, dated April 10, 2005, indicated that the Tong Krapeu (crocodile banner), also called Tong Rolauk (wave of water) or Tong Proleung, is used for funerals, for Phnom Ksach ceremony and generally for hanging in Wats. This banner represents a state of excellence or best belief from time immemorial. This belief is symbolized by the two inseparable elements, i.e. Neang Kong Hing = Land = Mae (leader or mother) and a Crocodile = Water = Ba (man).



រូបទី ៣១: កាលព្រះរាជាផ្សងកន្ទោងរកកន្លែងតម្កល់អដ្ឋិធាតុរបស់ព្រះនាង
(Figure 31: The King used kantoang to find a place to enshrine Vorpheak's remains)

កន្ទោងបានបណ្តែតខ្លួនចុះមកក្រោមទន្លេវិញ លុះមកដល់កន្លែងមួយ កន្ទោងក៏ចតឈប់មួយរយៈ ហើយក្រុមតន្ត្រីពិណពាទ្យចាប់ប្រគំកង រំពងឡើង ទីនោះត្រូវបានហៅឈ្មោះថា កំពង់ពិណពាទ្យ ហៅក្លាយជា កំពង់ជើងពាទ្យវិញ ស្ថិតនៅក្នុងឃុំកោះខ្ញែរ ស្រុកសំបូរ ខេត្តក្រចេះ សព្វថ្ងៃនេះ។ កន្ទោងក៏ចេញដំណើរចុះមកក្រោមទៀត រហូតមកដល់ភូមិសំបូរ ទើបកន្ទោងឈប់ជាស្ថាពរពុំប្រែប្រួលទៅណាទៀតឡើយ។ ព្រះរាជាក៏ញ៉ាំងសេវកាមាត្យអោយបោះព្រះពន្លាជ័យនៅទីនោះ ដើម្បីកសាងព្រះស្តូបបញ្ចុះអដ្ឋិធាតុរបស់ព្រះនាង ។

The kantoang floated down river and then stopped for a while, and so the royal musical band called Pin Peat started to play the music immediately. This place is named Kampong Pin Peat, and later become Kampong Cheung Peat locates in Koh Knher commune, Sambor district, Kratie province. The kantoang continued to float further down the river and had finally stopped at Sambor village. So, The King ordered the Sevakamarts to establish a temporary royal residence there in order to construct the tower for enshrining his daughter's remains.



រូបទី ៣២: ដុំឥដ្ឋចេតិយខ្លះដែលបានបាក់បែក
(Figure 32: Some Stupa's broken bricks)

ក្រោយពីបានដឹងទីតាំងពិតប្រាកដ សំរាប់តម្កល់ព្រះអដ្ឋិធាតុរួចហើយ ព្រះរាជាទ្រង់បានចាត់អោយសេវកាមាត្យសង់ចេតិយជាមុន។ ចេតិយនោះត្រូវបានសង់ឡើងនាឆ្នាំ ១៥២៩ ដោយប្រើដុំឥដ្ឋធំហើយវែងជាងឥដ្ឋដែលមានបច្ចុប្បន្ននេះ ។ មានការបញ្ជាក់ថា ដើម្បីកសាងចេតិយនេះ បានមានការសម្លាប់ស្ត្រីមានផ្ទៃពោះជាច្រើននាក់ផងដែរ ដោយមានជំនឿថា ការធ្វើដូច្នេះនឹងនាំអោយព្រលឹងព្រះនាងមានឫទ្ធិអំណាចខ្លាំងពូកែ។

When reaching the area that was selected for Vorpheak's remains to be enshrined, the King ordered The Sevakamarts to build a stupa. The stupa was built in 1529, made of bricks that are larger and longer than ones being used in the present time. It is also said that in order to build this stupa, many pregnant women were murdered and placed in the foundation of the stupa, which was believed to make Vorpheak's soul more powerful.



រូបទី ៣៣: រូបចេតិយបច្ចុប្បន្ននេះ
(Figure 33: The real stupa)



រូបទី ៣៤: រូបសំណាកក្រពើនេនធន នៅក្បែរចេតិយ
(Figure 34: The effigy of the Thonn crocodile)



រូបទី ៣៥: ចារឹកទាក់ទងទៅនឹងចេតិយ
(Figure 35: The inscription about the Stupa)

# ការដកស្រង់ខ្លឹមសារផ្ទាំងស្រុងនៃចារឹកនៅចំពីមុខចេតិយ

## Quote of the Inscription in front of the Stupa

### ព្រះរាជចេតិយនេះ

ព្រះបាទអង្គចន្ទរាជាទ្រង់កសាងក្នុងឆ្នាំ ១៥២៩ ទ្រង់បានបញ្ចុះព្រះរាជអដ្ឋិធាតុធីតារបស់ព្រះអង្គ ព្រះនាមព្រះអង្គម្ចាស់អនុជាតិក្សត្រីយ៍វរភ័ក្ត្រ តមកបានបញ្ចុះព្រះរាជអដ្ឋិធាតុព្រះសត្ថាទី១[១៧] ព្រះជ័យជេដ្ឋាទី១[១៨] ព្រះរាជសំភារចៅពញាតូ[១៩] ព្រះនាងព្រះម៉ែយួបុប្ផាវតី[២០] និងព្រះរាជវង្សានុវង្សជាច្រើន លុះមកដល់ខែធ្នូ គ.ស ១៩៥៥ សម្តេចព្រះ ឧបយុវរាជ ន.សីហនុ ទ្រង់បានស្ថាបនាជាថ្មី[២១] ហើយទ្រង់បានសម្ពោធឆ្លងព្រះចេតិយនេះ នៅថ្ងៃទី ២ ១ 6[២២] ព.ស ២៤៩៩ ត្រូវនឹងថ្ងៃទី ៣០ មេសា ១៩៥៦ ។

### THIS ROYAL STUPA

Preah Ang Chan Reachea built it in 1529 and enshrined Vorpheak's remains and then bones of Satha 1,[17] Cheychetha 1,[18] Preah Reach Samphea Chao Ponhea To,[19] Preah Neang Preah Mae Yuo Bophavatey[20] and other royal families. Until December 1955, HRH Norodom Sihanouk had rebuilt[21] the Stupa and inaugurated on 2.6 B.E[22] (6 printed under the dot) 2499 or April 30, 1956.

---

[១៧] ព្រះអង្គមានព្រះនាមមួយទៀតគឺ បរមរាជាទី ៥ ជាបុត្រារបស់ព្រះបរមរាជា និងជាចៅរបស់ព្រះអង្គចន្ទរាជា គ្រងរាជ្យពី ១៥៧៦ - ១៥៨៦ ( សៀវភៅជនជាតិខ្មែរ ភាគ២ ដោយអង្គការស៊ីប៉ា ត្រង់ទំព័រទី ១៦ ) ។

[១៨] ជាបុត្ររបស់ព្រះសត្ថាទី ១ ( សៀវភៅជនជាតិខ្មែរ ភាគ ២ ដោយអង្គការ ស៊ីប៉ា ត្រង់ទំព័រទី ១៦ ) ។

[១៩] ព្រះអង្គជាចៅលួតរបស់ព្រះអង្គចន្ទរាជា ហើយទ្រង់បានគ្រងរាជ្យនៅកោះឃ្លោក ( ខ្សាច់កណ្តាល ) ពី ១៦២៩-១៦៣៤ ( សៀវភៅជនជាតិខ្មែរ ភាគ២ ដោយអង្គការស៊ីប៉ា ត្រង់ទំព័រទី ២២ ) ។

[២០] ជាមហេសីព្រះឧទ័យ ហើយព្រះឧទ័យគឺក៏ជាចៅរបស់ព្រះអង្គចន្ទរាជាដែរ ។

[២១] តាមការបញ្ជាក់របស់លោកតាថា ចេតិយនេះពុំមែនកសាងជាថ្មីទេ តាមពិតចេតិយចាស់គឺជាព្រះស្តូប ដែលពុំមានកំពូលដូចបច្ចុប្បន្ននេះទេ ហើយត្រូវបានធ្វើស្រោបពីលើចេតិយចាស់ ដោយដាក់អោយមានកំពូលដូចបានឃើញសព្វថ្ងៃនេះ ។

[២២] តាមក្បួន ច័ន្ទគតិគឺ លេខ២=ថ្ងៃច័ន្ទ ហើយលេខ៦ នៅក្រោមសញ្ញាខណ្ឌ = ៦រោជ និងលេខ៦នៅក្រោយសញ្ញាខណ្ឌ = ខែពិសាខ ។ ដូច្នេះ គេអានថា ថ្ងៃទី ២ ឬថ្ងៃច័ន្ទ ទី ៦រោជ ខែ ពិសាខ ។

17 He has another name, Barom Reachea 5. He is the son of Preah Ang Barom Reachea and is the grandson of Preah Ang Chan Reachea. He reigned from 1576– 1586 (Khmer Nation, 2nd series, by SIPAR, page 16)

18 The son of Preah Satha 1 (Khmer Nation, 2nd series, by SIPAR, page 16)

19 He is a great great grandson of Preah Ang Chan Reachea. He reigned in Koh Khloak island (Khsach Kandal) from 1629 – 1634 (Khmer Nation, 2nd series, by SIPAR, page 22)

20 The wife of Preah Outtey and Preah Outtey was the grandson of Preah Ang Chan Reachea

21 The Elders confirmed that the Stupa was not rebuilt but it was formerly a tower without crown-shaped top. This tower was completely covered with crown-shaped top as seen today.

22 The lunar system reads 2 = Monday, number 6 under the dot = 6 Roach, and number 6 behind the dot = month of Pisak. So, it is read that 2nd day or Monday, 6 Roach and the month of Pisak.



រូបទី ៣៦: រូបសំណាកលោកតាទស្សន៍ និង លោកតាក្បាលប្រាំបី
(Figure 36: The effigy of the Royal Prophet and Eight-Head Grandpa)

បន្ទាប់ពីកសាងចេតិយរួចរាល់ ព្រះរាជាបានអោយគេសាងសង់រោងបុណ្យប្រក់ស្បូវយ៉ាងស្រស់ស្អាតនៅក្បែរចេតិយនោះ ដោយមានសសរចំនួន១០០ដើម ។ ទស្សនាវដ្ដីអាថ៌កំបាំងបានបង្ហាញថា[២៣] ពួកស្រីស្នំព្រហ្មចារីចំនួន១០០នាក់ បានស្ម័គ្រចិត្តនៅតាមបំរើព្រះនាងក្រពុំឈូក ដោយបូជាជីវិតតាមសសរ១ម្នាក់ៗ រហូតគ្រប់សសរទាំង១០០ដើម។ ចំណែកឯហោរាព្រមបូជាជីវិតបំរើព្រះនាងនៅក្បែរចេតិយនោះ ទើបគេហៅថា លោកតាទស្សន៍និងកន្ទោងខៀវ ហើយលោកមេទ័ពពិជ័យសង្គ្រាម ក៏បានបូជាជីវិតតាមការពារព្រះនាងដែរ ដែលបច្ចុប្បន្ននេះគេនិយមហៅថា លោកតាក្បាលប្រាំបី ។ ក្រោយពីសាងសង់រោងបុណ្យរួចឱ្យពិធីបុណ្យធំក៏ត្រូវបានប្រារព្ធធ្វើឡើងនៅជិតមាត់ទន្លេដែលមានអ្នកចូលរួមដ៏ច្រើនកុះករ ។ នៅក្នុងពិធីបុណ្យនោះ ព្រះរាជាទ្រង់បានប្រសិទ្ធនាមរោងបុណ្យនោះថា "ព្រះវិហារធំ " លុះពេលក្រោយមកទៀតទីអារាមនេះក៏ត្រូវបានគេហៅថា "ព្រះវិហារធំសសរ ១០០ "។

After the completion of the stupa The King asked for a *rong bon* (a funeral shelter) to be built near the stupa. The rong bon was built consisting of 100 pillars with thatch roofing. The local Magazine Secret[23] noted 100 of Vorpheak's virgin maids voluntarily committed suicide to take care of her by having each of their souls embedded in one of the 100 pillars. The royal prophet, now known as Ta Tos, agreed to serve Vorpheak, and the highest military commander, popularly called Ta Kbal Prambei (eight-head grandpa) committed suicide to provide her protection. At that time of completion of the rong bon, a major ceremony was held just near the river bank. During the ceremony, the rong bon was named by The King as "Preah Vihear Thom", and later was renamed as "100-Pillar Preah Vihear Thom".

---

[២៣] ទស្សនាវដ្ដី អាថ៌កំបាំង ឆ្នាំទី ១ លេខទី៣ ចុះថ្ងៃទី ១៣ ប្រចាំខែ កញ្ញា - តុលា ឆ្នាំ ២០០៦ ត្រង់ទំព័រទី ២៥-២៧ ។

[23] The local Magazine SECRET, Volume 1, Issue No. 3, dated 13th September – October 2006, page 25-27



រូបទី ៣៧: ព្រះរាជាបានកសាងចេតិយ និង ព្រះវិហារ
(Figure 37: The King built a Stupa and a Preah Vihear)

ព្រះវិហារធំសសរ១០០ កាលពីនៅប្រក់ស្បូវនៅឡើយត្រូវបានរន្ទះភ្លើង បាញ់ឆេះអស់សសរចំនួន២៨ដើម នៅសល់តែ៧២ដើមប៉ុណ្ណោះ។ រីឯព្រះពុទ្ធបដិមាករនៅក្នុងព្រះវិហារធំនេះ ក៏ត្រូវភ្លើងឆេះឡើងរលោងស្រិល តែមិនមានខូចខាតទេ។ ព្រះពុទ្ធបដិមាករនេះមានព្រះកេសបួង ឡើងលើស្រួចដូចម្កុដ ក្រោយមកបានបាក់នៅខ្លី ហើយនៅជំនាន់ខ្មែរក្រហមក៏បានកំទេចចោលទាំងស្រុង ។

The 100-pillar Preah Vihear, with its thatched roof, was badly burned by a thunderstorm, destroying 28 pillars, leaving only 72 pillars in tact. Buddha's statue in this Vihear was also somewhat affected by the burning, the statue was fairly black and the long hair that was wrapped atop Buddha's head like a crown was broken. Later, the whole statue was totally damaged during the Khmer Rouge period.



រូបទី ៣៨: ព្រះវិហារធំសសរ១០០ និង ក្លោងទ្វារ នាពេលបច្ចុប្បន្ននេះ
(Figure 38: The current status of 100-Pillar Preah Vihear Thom and the Gate)

វត្តព្រះវិហារធំសសរ១០០[២៤] ត្រូវបានកសាងជាថ្មីទាំងស្រុងដោយមានលាបពណ៌មាស និងមានក្បាច់រចនាស្រស់ស្អាតខ្ពស់ត្រដែតត្រដឹមគួរឱ្យគយគន់ដោយស្នាដៃព្រះគ្រូចៅអធិការ ភិក្ខុសាមណេរ លោកតាអាចារ្យ គណៈកម្មការវត្ត ព្រមទាំងការជួយជ្រោមជ្រែងពីសំណាក់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល មន្ត្រីគ្រប់លំដាប់ថ្នាក់ សប្បុរសជនដែលជាពុទ្ធបរិស័ទ ជិតឆ្ងាយនៅក្នុងប្រទេស និងក្រៅប្រទេសផងដែរ ។ នាពេលបច្ចុប្បន្ន ព្រះវិហារនេះមានសសរស៊ីម៉ងត៍ សុទ្ធចំនួន ១១៦ដើម ។ រហូតមកដល់សព្វថ្ងៃនេះ ប្រជាពលរដ្ឋនៅតែមានជំនឿ និងមានការគោរពបូជា ចំពោះព្រះរាជចេតិយរបស់ព្រះនាងក្រពុំឈូក និងព្រះពុទ្ធបដិមាករ នៅក្នុងព្រះវិហារជាហូរហែ។

The 100-Pillar Preah Vihear Thom[24] was completely rebuilt, golden in color, excellent in design and extremely beautiful. It was rebuilt by efforts of the Wat's head-monk, the monks, Achars, the Wat Committee, and through the generous supports of the leaders of the Royal Government of Cambodia, government officials, and people from within Cambodia and Overseas. The Preah Vihear was rebuilt with 116 concrete pillars. Presently, it is still visited frequently by those worshipping the stupa and Buddha's statues.

[២៤] ស្ថិតនៅកៀនទន្លេមេគង្គនាត្រើយខាងកើត ក្នុងឃុំសំបូរ ស្រុកសំបូរ ខេត្តក្រចេះ មានចំងាយ ៣៦គ.ម ពីទីរួមខេត្តក្រចេះ ។ ព្រះវិហារធំសសរ១០០ដែលបានកសាងជាថ្មីនេះ ត្រូវបានដាក់សម្ពោធ និងបញ្ចុះសីមា នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ១៩៩៧ ។

[24] Locates on the eastern part of the Mekong river bank in Sambor commune, Sambor district, Kratie province, 36km from Kratie provincial town. This newly-rebuilt 100-Pillar Preah Vihear Thom was inaugurated on January 14, 1997.



រូបទី ៣៩: សសរព្រះវិហារបីដើមដែលនៅសល់
(Figure 39: Vihear's three pillars left)



រូបទី៤០: សសរវិហារវត្តវិហារគោក តាំងពីឆ្នាំ១១៤២
(Figure 40: Pillars of Vihear Koak since 1142)

ទោះបីជាបានឆ្លងកាត់សម័យ ប៉ុល ពត ដែលបានរុះរើព្រះវិហារ និងយកសសរឈើដើម្បីធ្វើជាស្ពាន និងបានកាត់ទៅជាកង់ៗក្តី បច្ចុប្បន្ននេះមាននៅសល់សសរឈើ៣ដើមគត់ដែលនៅតែរឹងមាំ។ សសរឈើទាំង៣ដើមដែលនីមួយៗមានប្រវែង ប្រហែល ៥ ម៉ែត្រ ត្រូវបានដាក់តាំងជាសាធារណៈ សំរាប់បង្ហាញដល់សាធារណជនទូទៅអាចទស្សនាបាន។ សសរទាំងនោះត្រូវបានធ្វើឡើងដោយឈើ ពិសេសម្យ៉ាងដែលអាចទុកបានជាច្រើនសតវត្សរ៍ មានឈ្មោះថា ឈើតាត្រៅ[២៥]។ យើងក៏អាចឃើញសសរដទៃទៀតផងដែរ នៅក្នុងវត្តមួយស្ថិតនៅខាងកើតវត្តព្រះវិហារធំ សសរ១០០ ឈ្មោះវត្តវិហារគោក ដែលនៅតែឈរយ៉ាងរឹងមាំ តាំងពីឆ្នាំ ១១៤២ ដើម្បីទ្រទ្រង់ព្រះវិហាររហូតដល់សព្វថ្ងៃនេះ។

Today, only three of the pillars remain intact even after the Pol Pot regime have dismantled the Vihear and used the pillars for the bridges and cut into pieces. The three pillars, about 5 meters in length have been left in the Wat for display. They were made from a special wood that last for centuries, called Ta Trao[25] wood. Similar pillars can be found very solidly in eastern Wat, Vihear Koak, stand still today supporting the Vihear or temple since 1142.

---

[២៥] វចនានុក្រមខ្មែររបស់សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ចុះថ្ងៃទី ១០ ធ្នូ ១៩៦៧ ( ព.ស. ២៥១១ ) ត្រង់ទំព័រ ២១៧ ពន្យល់ថា តាត្រៅ ជាឈ្មោះឈើធំមួយប្រភេទមានខ្លឹមជាប់ប្រើការបានយូរអង្វែង។

[25] Khmer Dictionary of Supreme Patriarch Chuon Nath Choatanheannoa, Published by Buddhist Institute, December 10, 1967 (B.E. 2511), page 217, explains that Ta Trao is a kind of large and hard wood that are useful and long lasting.

# អក្ខរាវិរុទ្ធភាសាខ្មែរសំខាន់ៗនៅក្នុងសៀវភៅនេះ

## KEY KHMER SPELLINGS IN THIS BOOK

| | | |
|---|---|---|
| ក្អែរចេញ | ប្រសិទ្ធនាម | សំងំ ឬសម្ងំ |
| កុដិ | បដិសណ្ឋារកិច្ច | សមណគោតម |
| កាឡា | ពិណពាទ្យ | សេវកាមាត្យ |
| ខ្សែសីមា | ពុទ្ធបរិស័ទ | សសរ |
| គម្ពីរ | ព្រះវិហារ | សម្ពោធ |
| ចេតិយ | ព្រះពន្លាជ័យ | ស្រីស្នំព្រហ្មចារី |
| ចារក្បាល | ព្រះរាជដំណាក់ផែ | ស្រីស្នំមេនំមេនាង |
| ចារឹក | ព្រះរាជវង្សានុវង្ស | សម្បូរសប្បាយ |
| ចេតនា | ព្រះមេរុ ឬព្រះមេន | ស៊ីម៉ងត៍ |
| ឆ្វាយរង្វេល | ព្រះកេស | សប្បុរសជន |
| ជ្រោមជ្រែង | ព្រះចៅអធិការ | សម្ភាស ឬសម្ភាសន៍ |
| ជម្រៅ | ព្រះពុទ្ធបដិមាករ | ស្ពាពរ |
| ជង្ហែ | ភីលៀង | សក្ខីភាព |
| ដងវែក ឬដងវ៉ែក | មនុស្សម្នា | ហេតុការណ៍ |
| តម្កល់ | ម្កុដ | ហោរា |
| តាត្រៅ | រាជបរិពារ ឬរាជបរិវារ | ហាមាត់ |
| តិរច្ឆាន | រាជិនី | ហូរហែ |
| តម្រង់ | រហើយ ឬល្ហើយ | អន្លង់ |
| បូជាព្រះសព | វប្បធម៌ | អដ្ឋិធាតុ |
| ប្រញាប់ | ស្គរ | អាថ៌កំបាំង |
| បញ្ជិះ | សុគត | អូរ |
| បដិសេធ ឬបដិសេធន៍ | សុខដុមរមនា | ឥដ្ឋ |
| ប្រគំ | សតវត្សរ៍ | ឧបយុវរាជ |







Interviews with elders in front of ...

# បញ្ជីសប្បុរសជនចិត្តសប្បុរសបោះពុម្ពសៀវភៅនេះសំរាប់តម្កល់នៅតាមវត្ត

# LIST OF CONTRIBUTORS FOR PUBLISHING THIS BOOK FOR THE WATS

| ល.រ | ឈ្មោះ | ទីលំនៅបច្ចុប្បន្ន/ទីកន្លែងកំណើត | ចំនួនសៀវភៅ |
|---|---|---|---|
| ១ | លោក អៀ អ៊ុល និង លោកស្រី អ៊ុង ស៊ីម៉ូណារី | ភ្នំពេញ | ៦០ ក្បាល |
| ២ | លោក អៀ ហុង និង លោកស្រី សេង លឿម ព្រមទាំងបុត្រ | បាត់ដំបង | ៧ ក្បាល |
| ៣ | ឧបាសិកា ទឹម ឡិញ និង ចៅ ព្រមទាំងចៅទួត | បាត់ដំបង | ៥ ក្បាល |
| ៤ | ឧបាសិកា ញ៉ែម យិន និង ឧបាសក អ៊ុង ចយ | ភ្នំពេញ | ២២ ក្បាល |
| ៥ | លោក ថា សុផល និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៤៥ ក្បាល |
| ៦ | លោក គង់ សៀកលី និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ២៣ ក្បាល |
| ៧ | ឧបាសិកា ពាង ណៃគីម និង ចៅ | កំពង់ចាម | ២២ ក្បាល |
| ៨ | ឧបាសក ឈុំ ឆុន និង ឧបាសិកា នួន យូរ ព្រមទាំងបុត្រ | កំពង់ចាម | ១៥ ក្បាល |
| ៩ | កញ្ញា ឈុំ ស៊ីរុំម | ភ្នំពេញ | ២២ ក្បាល |
| ១០ | កញ្ញា ឃុន ស្រីពៅ | ភ្នំពេញ | ១៥ ក្បាល |
| ១១ | កញ្ញា អ៊ិន ហៀន | ស្វាយរៀង | ៧ ក្បាល |
| ១២ | កញ្ញា ជា ដាឡា | ភ្នំពេញ | ៧ ក្បាល |
| ១៣ | លោកស្រី សោម ដានី និង ក្រុមគ្រួសារ | ភ្នំពេញ | ៧ ក្បាល |
| ១៤ | ឧបាសិកា ញ៉ែប សារ៉ឺ | ភ្នំពេញ | ១៥ ក្បាល |
| ១៥ | កញ្ញា ឃួន ច័ន្ទដួរេ | ភ្នំពេញ | ១៥ ក្បាល |
| ១៦ | កញ្ញា ទុយ មុនីរ៉េត និង ក្រុមគ្រួសារ | ភ្នំពេញ | ៣០ ក្បាល |
| ១៧ | កញ្ញា អេង រដ្ឋា | ភ្នំពេញ | ១៥ ក្បាល |
| ១៨ | កុមារី លី លីហ្សា | ភ្នំពេញ | ១៥ ក្បាល |
| ១៩ | លោក សេង វក | ភ្នំពេញ | ៧ ក្បាល |
| ២០ | លោកស្រី ស្រេង ភីរម្យ និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ២១ | លោក ខន ចាន់ថារ៉ូ | ភ្នំពេញ | ៧ ក្បាល |
| ២២ | លោក ដួង វីរ័ត្ន និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ២៣ | លោក ធូ ឈុនលាភ និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ២៤ | លោកស្រី ប៉ែន ហឿង | ភ្នំពេញ | ៧ ក្បាល |
| ២៥ | កញ្ញា ហ៊ុន លីម | ភ្នំពេញ | ៦ ក្បាល |
| ២៦ | លោក ឯម សុគន្ធ និង លោកស្រី ស៊ិន ច័ន្ទសំណាង ព្រមទាំងបុត្រ | ភ្នំពេញ | ៣០ ក្បាល |
| ២៧ | លោក ញ៉ែ រ៉េត និង ភរិយា ព្រមទាំងបុត្រ | បាត់ដំបង | ១០ ក្បាល |
| ២៨ | លោក ថាវ គីមសាន និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ២៩ | លោក ហុក លី | ភ្នំពេញ | ១០ ក្បាល |
| ៣០ | លោក សៀង សិទ្ធិ | ភ្នំពេញ | ១៥ ក្បាល |
| ៣១ | លោក អៀ ថារ៉ាឌី និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៥០ ក្បាល |
| ៣២ | លោក សរ ចាន់ណា និង ភិរយា ព្រមទាំងបុត្រ | កំពង់ស្ពឺ | ៧ ក្បាល |

| ល.រ | ឈ្មោះ | ទីលំនៅបច្ចុប្បន្ន/ ទីកន្លែងកំណើត | ចំនួនសៀវភៅ |
|---|---|---|---|
| ៣៣ | លោក នួន វាសនា | ភ្នំពេញ | ៧ ក្បាល |
| ៣៤ | លោកស្រី កែវ សុភា | កំពង់ស្ពឺ | ៣ ក្បាល |
| ៣៥ | លោក ឡុងសេង លី និង ភរិយា ព្រមទាំងបុត្រ | កំពង់ស្ពឺ | ៧ ក្បាល |
| ៣៦ | លោក សុក្ក ត្រីស្នា និង ភរិយា ព្រមទាំងបុត្រ | កំពង់ស្ពឺ | ៧ ក្បាល |
| ៣៧ | លោកស្រី លុច សូភ៉ានី | ភ្នំពេញ | ៧ ក្បាល |
| ៣៨ | លោកស្រី ហៀង ស៊ីណែត និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ៣៩ | លោកស្រី អ៊ុច វន្ថា និង បុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៤០ | លោក សួស ប៊ុច និង លោកស្រី ឡាយ ឈិន ព្រមទាំងបុត្រ | កំពង់ស្ពឺ | ១៥ ក្បាល |
| ៤១ | លោក អ៊ឹង បូផាន់ណារ៉ា និង ភរិយា ព្រមទាំងបុត្រ | ប៉ារីស-បារាំង | ៤០ ក្បាល |
| ៤២ | លោក Yves និងលោកស្រី Mirjana LABBÉ ព្រមទាំងបុត្រ | ប្រទេសបារាំង | ៤០ ក្បាល |
| ៤៣ | កុមារី អ៊ីល ច័ន្ទពេជ្រលក្ខិណា | ភ្នំពេញ | ៧ ក្បាល |
| ៤៤ | កញ្ញា ប៊ុច វុទ្ធី | ភ្នំពេញ | ៧ ក្បាល |
| ៤៥ | លោក ប៊ុល ម៉ាទិន និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៤៦ | លោកស្រី សៀង សត្យា និង ស្វាមី ព្រមទាំងបុត្រ | កណ្ដាល | ៣០ ក្បាល |
| ៤៧ | លោក អ៊ឹង ម៉ូរាណា និង លោកស្រី ជា រ៉ានី ព្រមទាំងបុត្រ | កំពង់ស្ពឺ | ៧ ក្បាល |
| ៤៨ | លោក អ៊ឹង កាំ និង លោកស្រី ទីវ ធារី ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៤៩ | លោកស្រី អ៊ឹង គិញ និង លោក ម៉ែន រិន ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៥០ | លោកស្រី អ៊ឹង លាំង និងលោក សៅ សុភា ព្រមទាំងបុត្រ | ភ្នំពេញ | ៤៥ ក្បាល |
| ៥១ | លោកតា សោ ម៉ុន និង លោកយាយ លឹម វួចឡេង | ក្រចេះ | ១០ ក្បាល |
| ៥២ | លោកតា មេច សាញ់ និង លោកយាយ សុខ ភាង | ក្រចេះ | ៣ ក្បាល |
| ៥៣ | លោកតា ម៉ៅ គឹមហ៊ាន និង លោកយាយ ម៉ឹង សំអិត | ក្រចេះ | ៣ ក្បាល |
| ៥៤ | លោកតា អ៊ុង ស៊ាន | ក្រចេះ | ៣ ក្បាល |
| ៥៥ | លោកតា អិន ច័ន្ទមេសា | ក្រចេះ | ៣ ក្បាល |
| ៥៦ | លោកតា ហ៊ុក សាមឿន | ក្រចេះ | ២ ក្បាល |
| ៥៧ | លោកតា គង់ គឹម | ក្រចេះ | ៣ ក្បាល |
| ៥៨ | លោកតា ងិន ហេន | ក្រចេះ | ៣ ក្បាល |
| ៥៩ | លោកតា ហ៊ុយ គឹមហ៊ន | ក្រចេះ | ២ ក្បាល |
| ៦០ | លោកតា ទុំ នាង | ក្រចេះ | ២ ក្បាល |
| ៦១ | លោកតា អ៊ុក ឌឿន និង លោកយាយ អ៊ិន ណាលី | ក្រចេះ | ២ ក្បាល |
| ៦២ | លោកតា ទិត អិន | ក្រចេះ | ២ ក្បាល |
| ៦៣ | លោក ញ៉ អាន និងលោកស្រី កែវ វុត្ថា | ក្រចេះ | ៥ ក្បាល |
| ៦៤ | កញ្ញា សុខ ចិន្តា | ភ្នំពេញ | ១៥ ក្បាល |
| ៦៥ | កញ្ញា សួង ពុទ្ធី | ភ្នំពេញ | ៧ ក្បាល |
| ៦៦ | លោកស្រី ទូច សេដ្ឋា និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៦៧ | លោក ចាន់ ឆវីរ័ក្ខ និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៤៥ ក្បាល |
| ៦៨ | លោក ជ្រា វណ្ណរិទ្ធ | ភ្នំពេញ | ១៥ ក្បាល |

| ល.រ | ឈ្មោះ | ទីលំនៅបច្ចុប្បន្ន/ ទីកន្លែងរស់នៅ | ចំនួនសៀវភៅ |
|---|---|---|---|
| ៦៩ | លោកស្រី ភួង សុផល | ភ្នំពេញ | ១០ ក្បាល |
| ៧០ | លោកស្រី ញ៉ឹម ភក្តី | ភ្នំពេញ | ១០ ក្បាល |
| ៧១ | លោក សេង សារុន និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ៧២ | លោកស្រី ឌិន សុភាព និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ២០ ក្បាល |
| ៧៣ | លោក ប៊ុត បុណ្យរ័ត្ន | ភ្នំពេញ | ៥ ក្បាល |
| ៧៤ | លោក ម៉ក់ រ៉េមីស្សា និង ភរិយា ព្រមទាំងបុត្រ | កណ្ដាល | ១៥ ក្បាល |
| ៧៥ | លោក ជួន សុភាព | ភ្នំពេញ | ៥ ក្បាល |
| ៧៦ | លោក យិន ម៉េងយាង និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៥ ក្បាល |
| ៧៧ | លោក ឡាច សារី | ភ្នំពេញ | ១៥ ក្បាល |
| ៧៨ | លោក អ៊ុង ចាន់ប៊ុន | ភ្នំពេញ | ១៥ ក្បាល |
| ៧៩ | លោក មួង ណារ៉ាត់ | សហរដ្ឋអាមេរិក | ១៥០ ក្បាល |
| ៨០ | លោកស្រី នី រដ្ឋា និង បុត្រ ព្រមទាំងចៅ | ភ្នំពេញ | ១៥ ក្បាល |
| ៨១ | លោក សៀង សារៀន និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៨២ | លោក និន សិរីទ្ធិ និង ភរិយា | ភ្នំពេញ | ១៥ ក្បាល |
| ៨៣ | លោកស្រី សៀ ធារមី និង បុត្រ | ភ្នំពេញ | ៧ ក្បាល |
| ៨៤ | លោក សុខ សុវណ្ណ និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៧ ក្បាល |
| ៨៥ | លោកស្រី ខាំ សុទ្ធារី និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៨៦ | លោក គង់ ប៊ុណ្ណា និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ៨៧ | លោក យឹម មាន | ភ្នំពេញ | ១៥ ក្បាល |
| ៨៨ | លោក ហាង វិបុល | ភ្នំពេញ | ៣០ ក្បាល |
| ៨៩ | លោក Marc និងលោកស្រី Bophany PADOVANI ព្រមទាំងបុត្រ | ប្រទេសបារាំង | ៤០ ក្បាល |
| ៩០ | លោកស្រី អ៊ុក ចិត្រា និង ស្វាមី | ភ្នំពេញ | ៥ ក្បាល |
| ៩១ | លោក ឈ្លាង សារិត និង លោកស្រី កែវ ម៉ាលី ព្រមទាំងបុត្រ | ភ្នំពេញ | ៣០ ក្បាល |
| ៩២ | លោក ហឹម សុខាន់ណារ៉ូ | ភ្នំពេញ | ១៥ ក្បាល |
| ៩៣ | កញ្ញា ជា សុខនី | ពោធិ៍សាត់ | ១៥ ក្បាល |
| ៩៤ | លោកស្រី កង សុវណ្ណា និង ស្វាមី ព្រមទាំងបុត្រ | ពោធិ៍សាត់ | ១៥ ក្បាល |
| ៩៥ | កញ្ញា Megan MacInnes | ប្រទេសអង់គ្លេសនូវែលសេឡង់ | ៣០ ក្បាល |
| ៩៦ | លោកស្រី ឆាយ ពិដោរ និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ៩៧ | កញ្ញា លាង កញ្ញា | ភ្នំពេញ | ១៥ ក្បាល |
| ៩៨ | លោកស្រី សួន ប៊ុណ្ណា និង បុត្រ | ភ្នំពេញ | ៧ ក្បាល |
| ៩៩ | កញ្ញា សួន សុទ្ធារី | ភ្នំពេញ | ១៥ ក្បាល |
| ១០០ | កញ្ញា កុល លក្ខណា | ភ្នំពេញ | ៦ ក្បាល |
| ១០១ | លោក គង់ ធា និង ភរិយា ព្រមទាំងបុត្រ | កំពង់ចាម | ៧ ក្បាល |
| ១០២ | លោកស្រី សោ វណ្ណារ៉ា | កំពង់ចាម | ៧ ក្បាល |
| ១០៣ | លោក ស៊ិន សម្បូរ និង លោកស្រី អ៊ុន សារ៉ាន់ | ក្រុងព្រះសីហនុ | ១៥ ក្បាល |
| ១០៤ | កញ្ញា សំ ណារុន | កំពត | ៥ ក្បាល |

| ល.រ | ឈ្មោះ | ទីលំនៅបច្ចុប្បន្ន/ទីកន្លែងកំណើត | ចំនួនសៀវភៅ |
|---|---|---|---|
| ១០៥ | លោក ឈឹម ភ័ណ្ឌ និង លោក ឈឹម ភីន | កំពង់ចាម | ៥ ក្បាល |
| ១០៦ | លោក គ្រី ប៊ុនណេន | កំពង់ចាម | ៥ ក្បាល |
| ១០៧ | លោក សេង តេង និង ភរិយា | ក្រុងព្រះសីហនុ | ៣ ក្បាល |
| ១០៨ | កុមារា ពៅ សាំបា | ភ្នំពេញ | ៣ ក្បាល |
| ១០៩ | លោកស្រី ញ៉ែម ម៉ាឡែន និង បុត្រ | ភ្នំពេញ | ៣ ក្បាល |
| ១១០ | លោកស្រី សំ សារ៉ូន និង បុត្រ ព្រមទាំងចៅ | ពោធិសាត់ | ១៥ ក្បាល |
| ១១១ | លោក គង់ សេដ្ឋ និង ភរិយា ព្រមទាំងបុត្រ | កំពង់ឆ្នាំង | ១៥ ក្បាល |
| ១១២ | លោក ម៉ាត់ សារុំ និង លោកស្រី ច័ន្ទ ផល្លា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ១១៣ | លោកស្រី សុង ច័ន្ទពិសី និង បុត្រ | ភ្នំពេញ | ៧ ក្បាល |
| ១១៤ | លោកស្រី ផុន ភើយ និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ៦ ក្បាល |
| ១១៥ | លោក អ៊ុំ ណារិន្ទ និង ភរិយា ព្រមទាំងបុត្រ | បាត់ដំបង | ២០ ក្បាល |
| ១១៦ | ឧបាសិកា ហ៊ី ផល្លី និង បុត្រ ព្រមទាំងចៅ | បាត់ដំបង | ១៥ ក្បាល |
| ១១៧ | កញ្ញា គា ម៉ាឡែន | ភ្នំពេញ | ៧ ក្បាល |
| ១១៨ | លោកស្រី យឹម នីម៉ូល្លា និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ១១៩ | កញ្ញា សៅ ស៊ីថា | ភ្នំពេញ | ៧ ក្បាល |
| ១២០ | លោក ជីន វិចិត្រ និង ភរិយា | ភ្នំពេញ | ១៥ ក្បាល |
| ១២១ | លោកស្រី ឡុង គី និង ស្វាមី | សៀមរាប | ១៥ ក្បាល |
| ១២២ | លោក ចៅ សុខា និង លោកស្រី ច័ន្ទ ស៊ីឡែន ព្រមទាំងបុត្រ | បាត់ដំបង | ៩ ក្បាល |
| ១២៣ | លោក ញ៉ែម សុទ្ធា | ស្វាយរៀង | ១៥ ក្បាល |
| ១២៤ | លោក សុក សីហា និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ៣ ក្បាល |
| ១២៥ | លោក ប៊ិន សាន និង លោកស្រី នាង មុំ | ភ្នំពេញ | ៣ ក្បាល |
| ១២៦ | លោកស្រី យឹម វណ្ណៈ និង ស្វាមី ព្រមទាំងបុត្រ | ព្រៃវែង | ៧ ក្បាល |
| ១២៧ | កញ្ញា មាស សារុន | ស្វាយរៀង | ៧ ក្បាល |
| ១២៨ | កញ្ញា ង៉ាន់ ស៊ីដែន | ភ្នំពេញ | ៥ ក្បាល |
| ១២៩ | លោក ព្រហ្ម ហាស់ | បន្ទាយមានជ័យ | ៣០ ក្បាល |
| ១៣០ | លោក ពេញ ហឿន និង លោកស្រី ថូ ចាន់ | ភ្នំពេញ | ៧ ក្បាល |
| ១៣១ | លោកតា ប្រោណ ម៉ៅ និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១០ ក្បាល |
| ១៣២ | លោក ជា លាង និង លោកស្រី ម៉េង គីមសេង ព្រមទាំងបុត្រ | ភ្នំពេញ | ១៤ ក្បាល |
| ១៣៣ | លោក ហៀង ឈាងយី | ភ្នំពេញ | ៧ ក្បាល |
| ១៣៤ | លោក អ៊ុក សាំង និង លោកស្រី ណេប ជឿន | ភ្នំពេញ | ៩ ក្បាល |
| ១៣៥ | លោក មាស សុភាព និង លោកស្រី ជៀម សុវណ្ណនី | ភ្នំពេញ | ៧ ក្បាល |
| ១៣៦ | លោក អ៊ុក វិសុទ្ធ និង លោកស្រី មាស តុលា | ភ្នំពេញ | ១០ ក្បាល |
| ១៣៧ | លោក ឌិត សារ៉េត | ភ្នំពេញ | ៧ ក្បាល |
| ១៣៨ | លោក ឡាយ សុខហេង | ភ្នំពេញ | ៣ ក្បាល |
| ១៣៩ | លោក ឈាង វណ្ណារុំ | ភ្នំពេញ | ៣ ក្បាល |
| ១៤០ | លោកស្រី ម៉ែន វណ្ណារី | ភ្នំពេញ | ៥ ក្បាល |

| | | | |
|---|---|---|---|
| ១៤១ | បុគ្គលិកទាំងអស់នៃមជ្ឈមណ្ឌលប្រជាពលរដ្ឋ ដើម្បីអភិវឌ្ឍន៍ និងសន្តិភាព (ភីឌីភី) | ភ្នំពេញ | ៣០ ក្បាល |
| ១៤២ | លោក ស៊ុន សេង និង លោកស្រី អ៊ឹម ចាន់ថា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ១៤៣ | លោក សូ សំអុល និង លោកស្រី ចាន់ សំអុល | ក្រចេះ | ១៥ ក្បាល |
| ១៤៤ | កញ្ញា សូស៊ាង សុធារី | ភ្នំពេញ | ១៥ ក្បាល |
| ១៤៥ | កញ្ញា ស៊ុន ចាន់សែន | ភ្នំពេញ | ១៥ ក្បាល |
| ១៤៦ | លោក ស្មិត ប៉ែនចំរើន និង ភរិយា ព្រមទាំងបុត្រ | បាត់ដំបង | ១៥ ក្បាល |
| ១៤៧ | បុគ្គលិកទាំងអស់នៃអង្គការក្រុមអភិវឌ្ឍន៍ភូមិ | បាត់ដំបង | ២០ ក្បាល |
| ១៤៨ | លោកស្រី អ៊ិត ពៅ និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ២០ ក្បាល |
| ១៤៩ | លោក សួស សិរិត និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១៥ ក្បាល |
| ១៥០ | លោក តឹក វណ្ណារ៉ា | ភ្នំពេញ | ១៥ ក្បាល |
| ១៥១ | ឧបាសក វឹម យន់ និង ឧបាសិកា នូ នឹម និងបុត្រ ព្រមទាំងចៅ | កណ្ដាល | ២៥០ ក្បាល |
| ១៥២ | ឧបាសក លាភ អួន និង ឧបាសិកា សូ សុខន និងបុត្រ ព្រមទាំងចៅ | កណ្ដាល | ២៥០ ក្បាល |
| ១៥៣ | ឧបាសក សូ ប៊ុន និង ឧបាសិកា ជា សាម៉េន និងបុត្រ ព្រមទាំងចៅ | កណ្ដាល | ២០០ ក្បាល |
| ១៥៤ | លោកស្រី កែវ ម៉ារ៉ា និង ស្វាមី ព្រមទាំងបុត្រ | ភ្នំពេញ | ៧ ក្បាល |
| ១៥៥ | លោក សំ សុផល | ភ្នំពេញ | ៣ ក្បាល |
| ១៥៦ | លោក ខៀន សុខខេង | ភ្នំពេញ | ៥ ក្បាល |
| ១៥៧ | លោក ប៊ុនរឿង សុងម៉ាម និង ភរិយា ព្រមទាំងបុត្រ | ភ្នំពេញ | ១០០ ក្បាល |
| ១៥៨ | លោក អ៊ឹង រតនៈ | ភ្នំពេញ | ៧ ក្បាល |
| | | សរុប | ២.៩៣០ ក្បាល |

CATALOGED IN ALEPH
No: 28633
Date 16-06-14